| 19 | Xã Thạnh Quới | 28 | *Đơn vị bầu cử số 2:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 6:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 20 | Xã Thạnh An | 17 | *Đơn vị bầu cử số 2:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 6:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 21 | Xã Thạnh Phú | 17 | *Đơn vị bầu cử số 2:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 7:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 22 | Xã Trung Hưng | 27 | *Đơn vị bầu cử số 2:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 7:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 23 | Xã Thới Hưng | 9 | *Đơn vị bầu cử số 2:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 7:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 24 | Xã Cờ Đỏ | 25 | *Đơn vị bầu cử số 2:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 7:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 25 | Xã Đông Thuận | 16 | *Đơn vị bầu cử số 2:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 8:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 26 | Xã Đông Hiệp | 17 | *Đơn vị bầu cử số 2:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 8:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 27 | Xã Thới Lai | 26 | *Đơn vị bầu cử số 2:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 8:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 28 | Xã Trường Xuân | 23 | *Đơn vị bầu cử số 2:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 8:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 29 | Xã Trường Thành | 23 | *Đơn vị bầu cử số 1:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 9:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 30 | Xã Trường Long | 20 | *Đơn vị bầu cử số 1:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 9:* Ứng cử 5 đại biểu; Được bầu 3 đại biểu |

| STT | Đơn vị hành chính cấp xã, phường | Số lượng Tổ bầu cử | Số lượng phân bổ đại biểu Quốc hội khóa XVI | Số lượng đại biểu HĐND cấp thành phố |
|---|---|---|---|---|
| 31 | Xã Phong Điền | 34 | *Đơn vị bầu cử số 1:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 9:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 32 | Xã Nhơn Ái | 24 | *Đơn vị bầu cử số 1:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 9:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 33 | Xã Thạnh Xuân | 25 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 10:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 34 | Xã Tân Hòa | 23 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 10:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 35 | Xã Trường Long Tây | 18 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 10:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 36 | Xã Vị Thanh 1 | 39 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 11:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 37 | Phường Vị Tân | 20 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 11:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 38 | Phường Vị Thanh | 19 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 11:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 39 | Xã Hỏa Lựu | 19 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 12:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 40 | Xã Vĩnh Viễn | 13 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 12:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 41 | Xã Lương Tâm | 15 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 12:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 42 | Xã Xà Phiên | 19 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 12:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 43 | Xã Vĩnh Thuận Đông | 23 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 13:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 44 | Xã Vị Thủy | 23 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 13:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 45 | Xã Vĩnh Tường | 25 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 13:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 46 | Xã Hòa An | 21 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 13:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 47 | Phường Long Bình | 13 | *Đơn vị bầu cử số 3:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 14:* Ứng cử 5 đại biểu; Được bầu 3 đại biểu |

| STT | Đơn vị hành chính cấp xã, phường | Số lượng Tổ bầu cử | Số lượng phân bổ đại biểu Quốc hội khóa XVI | Số lượng đại biểu HĐND cấp thành phố |
|---|---|---|---|---|
| 48 | Phường Long Mỹ | 21 | *Đơn vị bầu cử số 3:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 14:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 49 | Phường Long Phú 1 | 21 | *Đơn vị bầu cử số 3:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 14:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 50 | Xã Phương Bình | 29 | *Đơn vị bầu cử số 3:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 14:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 51 | Xã Hiệp Hưng | 20 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 15:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 52 | Xã Tân Phước Hưng | 20 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 15:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 53 | Phường Ngã Bảy | 20 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 15:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 54 | Phường Đại Thành | 23 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 15:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 55 | Xã Phụng Hiệp | 19 | *Đơn vị bầu cử số 3:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 16:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 56 | Xã Tân Bình | 24 | *Đơn vị bầu cử số 3:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 16:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 57 | Xã Thạnh Hòa | 60 | *Đơn vị bầu cử số 3:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 16:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 58 | Xã Đông Phước | 26 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 17:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 59 | Xã Châu Thành | 19 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 17:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 60 | Xã Phú Hữu | 22 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 17:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 61 | Xã An Lạc Thôn | 34 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 18:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 62 | Xã Phong Nẫm | 6 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 18:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 63 | Xã Thới An Hội | 24 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 18:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 64 | Xã Nhơn Mỹ | 34 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 18:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |

| STT | Đơn vị hành chính cấp xã, phường | Số lượng Tổ bầu cử | Số lượng phân bổ đại biểu Quốc hội khóa XVI | Số lượng đại biểu HĐND cấp thành phố |
|---|---|---|---|---|
| 65 | Xã Kế Sách | 31 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 18:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 66 | Xã Đại Hải | 29 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 19:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 67 | Xã Hồ Đắc Kiện | 25 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 19:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 68 | Xã Phú Tâm | 25 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 19:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 69 | Xã Thuận Hòa | 12 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 19:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 70 | Xã An Ninh | 26 | *Đơn vị bầu cử số 4:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 19:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 71 | Xã Mỹ Hương | 35 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 20:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 72 | Xã Mỹ Tú | 24 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 20:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 73 | Xã Long Hưng | 22 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 20:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 74 | Xã Mỹ Phước | 14 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 20:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 75 | Phường Ngã Năm | 43 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 21:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 76 | Xã Tân Long | 22 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 21:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 77 | Phường Mỹ Quới | 27 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 21:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 78 | Xã Vĩnh Lợi | 22 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 22:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 79 | Xã Phú Lộc | 35 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 22:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 80 | Xã Lâm Tân | 19 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 22:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 81 | Xã Gia Hòa | 36 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 22:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |

| STT | Đơn vị hành chính cấp xã, phường | Số lượng Tổ bầu cử | Số lượng phân bổ đại biểu Quốc hội khóa XVI | Số lượng đại biểu HĐND cấp thành phố |
|---|---|---|---|---|
| 82 | Xã Nhu Gia | 39 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 23:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 83 | Xã Hòa Tú | 26 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 23:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 84 | Xã Ngọc Tố | 37 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 23:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 85 | Xã Thạnh Thới An | 18 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 23:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 86 | Xã Lai Hòa | 16 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 24:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 87 | Phường Vĩnh Phước | 28 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 24:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 88 | Phường Vĩnh Châu | 36 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 24:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 89 | Xã Vĩnh Hải | 15 | *Đơn vị bầu cử số 5:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 24:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 90 | Phường Khánh Hòa | 31 | *Đơn vị bầu cử số 6:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 25:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 91 | Xã Lịch Hội Thượng | 13 | *Đơn vị bầu cử số 6:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 25:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 92 | Xã Liêu Tú | 22 | *Đơn vị bầu cử số 6:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 25:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 93 | Xã Tài Văn | 27 | *Đơn vị bầu cử số 6:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 25:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 94 | Xã Trần Đề | 31 | *Đơn vị bầu cử số 6:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 26:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 95 | Xã Cù Lao Dung | 32 | *Đơn vị bầu cử số 6:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 26:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 96 | Xã An Thạnh | 26 | *Đơn vị bầu cử số 6:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 26:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 97 | Xã Long Phú | 17 | *Đơn vị bầu cử số 6:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 27:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |
| 98 | Xã Tân Thạnh | 26 | *Đơn vị bầu cử số 6:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu | *Đơn vị bầu cử số 27:*<br>Ứng cử 5 đại biểu;<br>Được bầu 3 đại biểu |

| STT | Đơn vị hành chính cấp xã, phường | Số lượng Tổ bầu cử | Số lượng phân bổ đại biểu Quốc hội khóa XVI | Số lượng đại biểu HĐND cấp thành phố |
|---|---|---|---|---|
| 99 | Xã Đại Ngãi | 18 | *Đơn vị bầu cử số 6:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 27:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 100 | Xã Trường Khánh | 27 | *Đơn vị bầu cử số 6:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 27:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 101 | Phường Sóc Trăng | 34 | *Đơn vị bầu cử số 6:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 28:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 102 | Phường Phú Lợi | 41 | *Đơn vị bầu cử số 6:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 28:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| 103 | Phường Mỹ Xuyên | 33 | *Đơn vị bầu cử số 6:* Ứng cử 5 đại biểu; Được bầu 3 đại biểu | *Đơn vị bầu cử số 28:* Ứng cử 5 đại biểu; Được bầu 3 đại biểu |
| **Tổng số Tổ bầu cử:** | | **2.597** | | |

**Câu 32.** Một số khẩu hiệu tuyên truyền bầu cử đại biểu Quốc hội khóa XVI và đại biểu Hội đồng nhân dân các cấp nhiệm kỳ 2026 - 2031?

**Đáp:**

Một số khẩu hiệu tuyên truyền bầu cử đại biểu Quốc hội khóa XVI và đại biểu Hội đồng nhân dân các cấp nhiệm kỳ 2026 - 2031 là:

1. Nhiệt liệt chào mừng Ngày bầu cử đại biểu Quốc hội khóa XVI và đại biểu Hội đồng nhân dân các cấp nhiệm kỳ 2026 - 2031!
2. Ngày 15-3-2026, cử tri cả nước đi bầu cử đại biểu Quốc hội khóa XVI và đại biểu Hội đồng nhân dân các cấp nhiệm kỳ 2026 - 2031!
3. Bầu cử đại biểu Quốc hội khóa XVI và đại biểu Hội đồng nhân dân các cấp nhiệm kỳ 2026 - 2031 là Ngày hội của toàn dân!
4. Ngày bầu cử là Ngày hội đại đoàn kết toàn dân tộc!
5. Ngày bầu cử - Ngày hội của niềm tin, đoàn kết và khát vọng Việt Nam!
6. Bầu cử góp phần xây dựng Nhà nước pháp quyền xã hội chủ nghĩa Việt Nam vững mạnh!
7. Bầu cử để chọn người có tâm, có tầm, tận tụy phục vụ Nhân dân!
8. Phát huy quyền làm chủ của Nhân dân thông qua bầu cử dân chủ, công khai, minh bạch!
9. Tham gia bầu cử đại biểu Quốc hội khóa XVI và đại biểu Hội đồng nhân dân các cấp nhiệm kỳ 2026 - 2031 là quyền lợi, nghĩa vụ thiêng liêng của mỗi công dân!
10. Sáng suốt lựa chọn người xứng đáng đại diện cho Nhân dân!
11. Cử tri thành phố Cần Thơ tích cực tham gia bầu cử đại biểu Quốc hội khóa XVI và đại biểu Hội đồng nhân dân các cấp nhiệm kỳ 2026 - 2031!
12. Mỗi lá phiếu là một niềm tin, một trách nhiệm đối với Tổ quốc!
13. Sáng suốt lựa chọn những người đủ đức, đủ tài vào Quốc hội và Hội đồng nhân dân!
14. Cử tri cả nước đồng lòng bầu cử, chung tay xây dựng đất nước giàu mạnh!
15. Toàn dân tham gia bầu cử để góp phần xây dựng chính quyền trong sạch, vững mạnh!
16. Mỗi lá phiếu góp phần đưa đất nước phát triển hùng cường, thịnh vượng!
17. Quốc hội Việt Nam - Cơ quan đại biểu cao nhất của Nhân dân, cơ quan quyền lực Nhà nước cao nhất của nước Cộng hòa xã hội chủ nghĩa Việt Nam!
18. Quốc hội là biểu tượng sức mạnh tinh thần đại đoàn kết toàn dân tộc Việt Nam!
19. Quốc hội khóa XVI - hiện thân của trí tuệ, ý chí và nguyện vọng của Nhân dân!
20. Toàn Đảng bộ, toàn dân, toàn quân thành phố Cần Thơ thi đua lập thành tích chào mừng cuộc bầu cử đại biểu Quốc hội khóa XVI và đại biểu Hội đồng nhân dân các cấp nhiệm kỳ 2026 - 2031!
21. Đảng Cộng sản Việt Nam quang vinh muôn năm!
22. Nước Cộng hòa xã hội chủ nghĩa Việt Nam muôn năm!
23. Chủ tịch Hồ Chí Minh vĩ đại sống mãi trong sự nghiệp của chúng ta!

# ឯកសារឃោសនា
# ការបោះឆ្នោតតំណាងរាស្ត្រ នីតិកាលទី ១៦
# និងតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦-២០៣១
# នៅទីក្រុងកឹងធើ

---

**ជំពូកទី I - បញ្ហាទូទៅ**

**សំណួរ ១៖** តើការបោះឆ្នោតតំណាងរាស្ត្រ នីតិកាលទី១៦ និងតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦-២០៣១ មានខ្លឹមសារនយោបាយដូចម្តេច?

**ចម្លើយ៖**

ការបោះឆ្នោតតំណាងរាស្ត្រ និងតំណាងក្រុមប្រឹក្សាប្រជាជន គឺជាសិទ្ធិនយោបាយមួយក្នុងចំណោមសិទ្ធិនយោបាយមូលដ្ឋានរបស់ពលរដ្ឋបានចែងក្នុងរដ្ឋធម្មនុញ្ញ។ ការបោះឆ្នោតគឺជាមធ្យោបាយបង្ហាញពីឆន្ទៈ គោលបំណង និងសិទ្ធិជាម្ចាស់របស់ប្រជាជន ក្នុងការកសាងប្រទេសនីតិរដ្ឋសង្គមនិយមនិយាយរួម និងបង្កើតស្ថាប័នអំណាចរដ្ឋ នៅមជ្ឈិមនិងភូមិភាគនិយាយដោយឡែក។

ការបោះឆ្នោតតំណាងរាស្ត្រ នីតិកាលទី ១៦ និងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦-២០៣១ បានចាត់តាំងឡើងមួយថ្ងៃជាមួយគ្នាវិសាលភាពទូទាំងប្រទេស ក្នុងបរិការណ៍ដំណើរការផ្លាស់ថ្មីនៅប្រទេសយើង ក្រោយពី ៤០ឆ្នាំ សម្រេចបានសមិទ្ធផលដ៏ធំធេង និងមានអត្ថន័យជាប្រវត្តិសាស្ត្រលើគ្រប់វិស័យជីវភាព សង្គម; ទន្ទឹមនឹងនោះ សកម្មផ្សព្វផ្សាយអនុវត្តការរៀបចំរចនាសម្ព័ន្ធក្បាលម៉ាស៊ីនរបស់ប្រព័ន្ធនយោបាយ រៀបចំព្រំប្រទល់រដ្ឋបាលឡើងវិញ និងដំណើរការទម្រង់ រដ្ឋអំណាចភូមិភាគ២ថ្នាក់ ធានាឱ្យមានភាពតូចស្រាល សមស្រប រឹងមាំ មានសមត្ថភាព ប្រសិទ្ធភាព និងមានប្រសិទ្ធផល ដើម្បីឈានចូលយុគសម័យអភិវឌ្ឍន៍ថ្មីរបស់ជនជាតិ។ នេះជាព្រឹត្តិការណ៍នយោបាយដ៏សំខាន់របស់ប្រទេសជាតិ ប្រព្រឹត្តឡើងបន្ទាប់ពីមហាសន្និបាតទូទាំងប្រទេស លើកទី១៤ របស់បក្ស ជាជំហានធ្វើឱ្យទៅជាភាពជាក់ស្តែងនូវសេចក្តីសម្រេចចិត្ត ផ្សារភ្ជាប់នឹងកិច្ចការកម្មាភិបាលរបស់បក្ស ជាប់ពាក់ព័ន្ធនឹងការ

ទទួលខុសត្រូវរបស់គណៈ ផ្នែកគ្រប់ថ្នាក់; ជាកន្លែងដើម្បីអ្នកបោះឆ្នោត អនុវត្តសិទ្ធិជាម្ចាស់របស់ពលរដ្ឋ ជ្រើសរើសអ្នកតំណាងដ៏លេចធ្លោនិងស័ក្តិសមដើម្បីតំណាងឱ្យឆន្ទៈ គោលបំណង និងសិទ្ធិធ្វើម្ចាស់របស់ខ្លួននៅក្នុងរដ្ឋសភា និងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ក្នុងអាណត្តិកាលថ្មី រួមចំណែកយ៉ាងសកម្មក្នុងការកសាង ពង្រឹងនិងធ្វើឱ្យសុក្រឹតប្រទេសនីតិរដ្ឋសង្គមនិយមរបស់ប្រជាជន អាស្រ័យប្រជាជន ដើម្បីប្រជាជន ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តវៀតណាម។

**សំណួរ ២៖** តើក្រុមប្រឹក្សាប្រជាជនមានឋានៈ និងតួនាទីយ៉ាងដូចម្តេចនៅភូមិភាគ? តើអាណត្តិកាលរបស់ក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ បានកំណត់យ៉ាងដូចម្តេចដែរ?

**ចម្លើយ៖**

ក្រុមប្រឹក្សាប្រជាជន រួមមានតំណាងក្រុមប្រឹក្សាប្រជាជន អាស្រ័យអ្នកបោះឆ្នោតនៅភូមិភាគបោះឆ្នោតជ្រើសរើសជាស្ថាប័នអំណាច រដ្ឋនៅភូមិភាគ តំណាងឱ្យឆន្ទៈ គោលបំណង និងសិទ្ធិជាម្ចាស់របស់ប្រជាជន កំណត់សម្រេចនូវបញ្ហាសំខាន់ៗរបស់ភូមិភាគ ត្រួតពិនិត្យការគោរពតាមរដ្ឋធម្មនុញ្ញនិងច្បាប់ ត្រួតពិនិត្យសកម្មភាពរបស់ស្ថាប័នរដ្ឋនៅភូមិភាគ; ទទួលខុសត្រូវចំពោះប្រជាជននៅភូមិភាគនិងស្ថាប័នរដ្ឋថ្នាក់លើ។

អាណត្តិកាលរបស់ក្រុមប្រឹក្សាប្រជាជននៃនីតិកាលនីមួយៗ មានរយៈពេល ០៥ ឆ្នាំ គិតចាប់ពីថ្ងៃបើកសម័យប្រជុំលើកទីមួយរបស់ក្រុមប្រឹក្សាប្រជាជន នីតិកាលនោះ រហូតដល់ថ្ងៃបើកសម័យប្រជុំលើកទីមួយរបស់ក្រុមប្រឹក្សាប្រជាជននីតិកាលថ្មី។ ការបង្រួញឬអូសបន្លាយអាណត្តិកាលរបស់ក្រុមប្រឹក្សាប្រជាជន អាស្រ័យរដ្ឋសភាកំណត់សម្រេច តាមសំណើរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។

**សំណួរ ៣៖** តើតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជន ត្រូវឆ្លើយតបនឹងបទដ្ឋានអ្វីខ្លះ?

**ចម្លើយ៖**

តំណាងរដ្ឋសភាត្រូវឆ្លើយតបនឹងបទដ្ឋានបានកំណត់ក្នុងមាត្រា ២២ នៃច្បាប់ស្តីពីការរៀបចំរដ្ឋសភា ចំណែកតំណាងក្រុមប្រឹក្សាប្រជាជន ត្រូវឆ្លើយតបនឹងបទដ្ឋានដែលបានកំណត់ត្រង់កថាខណ្ឌ ៣ មាត្រា ៥ នៃច្បាប់ស្តីពីការរៀបចំរដ្ឋអំណាចភូមិភាគ។ នោះគឺ៖

- ស្មោះត្រង់ចំពោះមាតុភូមិ ប្រជាជន និងរដ្ឋធម្មនុញ្ញ; ខិតខំអនុវត្តដំណើរការផ្លាស់ថ្មី ដើម្បីទិសដៅប្រជាជនសម្បូររុងរឿង ប្រទេសជាតិរឹងមាំ ប្រជាធិបតេយ្យ សមភាព និងអារ្យធម៌;

- មានសញ្ជាតិមួយ គឺសញ្ជាតិវៀតណាម;

- មានលក្ខណៈសម្បត្តិ សីលធម៌ល្អ ឧស្សាហ៍ព្យាយាម សន្សំសំចៃ ស្មោះត្រង់ មិនគិតប្រយោជន៍សួនតួ និងជាគំរូគោរពច្បាប់; មានភាពក្លាហាន ប្តូរផ្តាច់ តស៊ូប្រឆាំងអំពើពុករលួយ ភាពខ្ជះខ្ជាយ ភាពក្រអឺតក្រទម អំណាចផ្តាច់ការ និងទង្វើល្មើសច្បាប់ផ្សេងៗទៀត;

- មានកម្រិតវិជ្ជា ឯកទេស មានសមត្ថភាពគ្រប់គ្រាន់ សុខភាព បទពិសោធន៍ការងារ និងប្រិយភាពដើម្បីអនុវត្តភារកិច្ច;

- មានទំនាក់ទំនងស្អិតល្មួតជាមួយប្រជាជន ស្តាប់មតិយោបល់របស់ប្រជាជន ហើយបានប្រជាជនជឿទុកចិត្ត;

- មានឱកាសចូលរួមក្នុងសកម្មភាពរបស់រដ្ឋសភា និងក្រុមប្រឹក្សាប្រជាជន។

ទន្ទឹមនឹងនោះ តំណាងក្រុមប្រឹក្សាប្រជាជន ថែមទាំងស្នាក់នៅឬបំពេញការងារនៅស្ថាប័នអង្គការ អង្គភាពឬសហគ្រាសនៅក្នុងអង្គភាពរដ្ឋបាលដែលខ្លួនជាតំណាងក្រុមប្រឹក្សាប្រជាជន។

**សំណួរ ៤៖** តើតំណាងក្រុមប្រឹក្សាប្រជាជនមានសិទ្ធិអ្វីខ្លះ?

**ចម្លើយ៖**

តំណាងក្រុមប្រឹក្សាប្រជាជនមានសិទ្ធិចោទសួរប្រធានគណៈកម្មាធិការប្រជាជន សមាជិកផ្សេងៗទៀតរបស់គណៈកម្មាធិការប្រជាជន ប្រធានស្ថាប័នចំណុះគណៈកម្មាធិការប្រជាជនកម្រិតដូចគ្នា ប្រធានតុលាការប្រជាជន និងប្រធានអយ្យការប្រជាជន តាមសេចក្តីកំណត់របស់ច្បាប់។

តំណាងក្រុមប្រឹក្សាប្រជាជន មានសិទ្ធិស្នើថ្មែប្រតិដ្ឋកសាងគោលនយោបាយនៅភូមិភាគ; សិទ្ធិស្នើរបស់ក្រុមប្រឹក្សាប្រជាជន បោះឆ្នោតទំនុកចិត្តចំពោះអ្នកកាន់តំណែងដែលក្រុមប្រឹក្សាប្រជាជនជ្រើសរើស; ស្នើចាត់តាំងកិច្ចប្រជុំប្រធានបទជំនាញ សម័យប្រជុំសម្ងាត់ ឬសម័យប្រជុំ

ដើម្បីដោះស្រាយបញ្ហាដែលកើតឡើងជាយថាហេតុ ហើយស្នើបញ្ហាផ្សេងៗទៀត ដែលអ្នកតំណាងយល់ថាចាំបាច់។

ពេលប្រទះឃើញមានទង្វើល្មើសច្បាប់ បង្កឱ្យខូចខាតផលប្រយោជន៍របស់រដ្ឋ សិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់អង្គការនិងបុគ្គល តំណាងក្រុមប្រឹក្សាប្រជាជនមានសិទ្ធិសំណូមពរស្ថាប័ន និងអង្គការជាប់ពាក់ព័ន្ធ អនុវត្តវិធានការចាំបាច់ដើម្បីបញ្ឈប់ការទង្វើល្មើសច្បាប់បានទាន់ពេល។

ពេលអនុវត្តភារកិច្ច និងសិទ្ធិអំណាចក្នុងនាមជាអ្នកតំណាង តំណាងក្រុមប្រឹក្សាប្រជាជនមានសិទ្ធិសំណូមពរស្ថាប័ន អង្គការ បុគ្គលផ្តល់ព័ត៌មាន និងឯកសារជាប់ទាក់ទងដល់ភារកិច្ចដែនសមត្ថកិច្ចរបស់ស្ថាប័ន អង្គការនិងបុគ្គលនោះ។

**សំណួរ ៥៖** តើកាតព្វកិច្ចរបស់ក្រុមប្រឹក្សាប្រជាជនបានកំណត់ដូចម្តេច ?

**ចម្លើយ៖**

តំណាងក្រុមប្រឹក្សាប្រជាជន មានកាតព្វកិច្ចចូលរួមរាល់កិច្ចប្រជុំឱ្យបានគ្រប់គ្រាន់ កិច្ចប្រជុំក្រុមប្រឹក្សាប្រជាជន ចូលរួមពិភាក្សានិងបោះឆ្នោតលើបញ្ហានានាចំណុះភារកិច្ច សមត្ថកិច្ចរបស់ក្រុមប្រឹក្សាប្រជាជន។ បើតំណាងក្រុមប្រឹក្សាប្រជាជនមិនចូលរួមក្នុងកិច្ចប្រជុំ ឬសម័យប្រជុំណាមួយត្រូវតែមានមូលហេតុ និងត្រូវរាយការណ៍ជាមុនដល់ប្រធានអង្គប្រជុំ ឬកិច្ចប្រជុំ។ ក្នុងករណីអ្នកតំណាងក្រុមប្រឹក្សាប្រជាជនអវត្តមានក្នុងសម័យប្រជុំក្នុង ០១ឆ្នាំ ដោយគ្មានហេតុផលត្រឹមត្រូវ ប្រចាំការក្រុមប្រឹក្សាប្រជាជន ត្រូវរាយការណ៍ដល់ក្រុមប្រឹក្សាប្រជាជនដើម្បីបញ្ឈប់តំណែងតំណាងក្រុមប្រឹក្សាប្រជាជននោះ។

តំណាងក្រុមប្រឹក្សាប្រជាជន ត្រូវទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកបោះឆ្នោតនៅកន្លែងដែលខ្លួនអនុវត្តភារកិច្ចជាអ្នកតំណាង ក្រោមការត្រួតពិនិត្យរបស់អ្នកបោះឆ្នោត សំណេះសំណាលជាមួយអ្នកបោះឆ្នោតជាប្រចាំ ដើម្បីស្វែងយល់ពីមតិ គោលបំណងរបស់អ្នកបោះឆ្នោត; ប្រមូលនិងឆ្លុះបញ្ចាំង ដោយស្មោះត្រង់នូវមតិ គោលបំណង និងសំណើរបស់អ្នកបោះឆ្នោតជាមួយក្រុមប្រឹក្សាប្រជាជន ស្ថាប័ន និងអង្គការជាប់ពាក់ព័ន្ធ; ការពារសិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់អ្នកបោះឆ្នោត។

បន្ទាប់ពីសម័យប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាប្រជាជន តំណាងក្រុមប្រឹក្សាប្រជាជនជួបសំណេះសំណាលជាមួយអ្នកបោះឆ្នោត ដើម្បីរាយការណ៍អំពីលទ្ធផលសម័យប្រជុំ ផ្សព្វផ្សាយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជាជន និងចលនាប្រជាជនអនុវត្តសេចក្តីសម្រេចចិត្តនោះ។

តំណាងក្រុមប្រឹក្សាប្រជាជន មានភារកិច្ចទទួលពលរដ្ឋតាមសេចក្តីកំណត់របស់ច្បាប់។ ពេលទទួលពាក្យបណ្តឹង ថ្កោលទោស សំណើនិងឆ្លុះបញ្ចាំងរបស់ពលរដ្ឋ តំណាងក្រុមប្រឹក្សាប្រជាជន មានការទទួលខុសត្រូវក្នុងការស្រាវជ្រាវ ណែនាំពលរដ្ឋផ្ញើពាក្យបណ្តឹង ថ្កោលទោស សំណើនិងឆ្លុះបញ្ចាំងត្រូវស្ថាប័ន អង្គការ បុគ្គលដែលមានសិទ្ធិដោះស្រាយ។ ក្នុងករណីចាំបាច់ តំណាងក្រុមប្រឹក្សាប្រជាជនផ្ទាល់ ឬឆ្លងរយៈប្រចាំការក្រុមប្រឹក្សាប្រជាជនដែលមានថ្នាក់ស្មើគ្នា បញ្ជូនលិខិតទៅស្ថាប័ន អង្គការមានសមត្ថកិច្ចដោះស្រាយ និងតាមដាន ដាស់តឿនការដោះស្រាយ។

**សំណួរ ៦៖** តើសិទ្ធិបោះឆ្នោតជាអ្វី? សិទ្ធិឈរឈ្មោះជាអ្វី?

**ចម្លើយ៖**

សិទ្ធិបោះឆ្នោត គឺជាសិទ្ធិមូលដ្ឋានរបស់ពលរដ្ឋតាមសេចក្តីកំណត់របស់ច្បាប់ ដើម្បីអនុវត្តសិទ្ធិជ្រើសរើសអ្នកតំណាងរបស់ខ្លួនចូលក្នុងស្ថាប័នអំណាចរដ្ឋ។ សិទ្ធិបោះឆ្នោត រួមមានការឧទ្ទេសនាមអ្នកឈរឆ្នោត និងបោះឆ្នោតជ្រើសរើសអ្នកតំណាងរបស់ខ្លួននៅរដ្ឋសភា និងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់។

សិទ្ធិឈរឆ្នោត គឺជាសិទ្ធិមូលដ្ឋានរបស់ពលរដ្ឋ ពេលឆ្លើយតបគ្រប់បទដ្ឋាន គ្រប់លក្ខណៈតាមសេចក្តីកំណត់របស់ច្បាប់ គឺអាចបង្ហាញពីគោលបំណងរបស់ខ្លួន បានឈរឆ្នោតតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជន។

មាត្រា ២៧ របស់រដ្ឋធម្មនុញ្ញនិងមាត្រា ២ ច្បាប់ស្តីពីការបោះឆ្នោតតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជន បានកំណត់៖ គិតដល់ថ្ងៃបោះឆ្នោតបានប្រកាស ពលរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម មានអាយុគ្រប់ ១៨ឆ្នាំឡើងទៅមានសិទ្ធិបោះឆ្នោតនិងមានអាយុគ្រប់ ២១ ឆ្នាំឡើងទៅ មានសិទ្ធិឈរឆ្នោតចូលក្នុងរដ្ឋសភា និងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់។

**សំណួរ ៧៖** តើហេតុអ្វីបានជានិយាយថា ការបោះឆ្នោតជាសិទ្ធិ និងជាកាតព្វកិច្ចរបស់ពលរដ្ឋ?

**ចម្លើយ៖**

សិទ្ធិបោះឆ្នោត គឺជាសិទ្ធិនយោបាយមូលដ្ឋានរបស់ពលរដ្ឋ បានចែងក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ ដើម្បីធានាជូនពលរដ្ឋគ្រប់រូបដែលគ្រប់លក្ខណៈអនុវត្តការជ្រើសរើសអ្នកតំណាងរបស់ខ្លួន ចូលស្ថាប័នអំណាចរដ្ឋ។ សិទ្ធិរបស់ពលរដ្ឋ គឺមិនអាចកាត់ផ្តាច់ចេញពីកាតព្វកិច្ចរបស់ពលរដ្ឋបានទេ។

ឆ្លងតាមរយៈបោះឆ្នោត ពលរដ្ឋបោះឆ្នោតដោយផ្ទាល់ដើម្បីជ្រើសរើសអ្នកតំណាងឱ្យឆន្ទៈគោលបំណងនិងសិទ្ធិជាម្ចាស់របស់ខ្លួន ជំនួសមុខខ្លួនអនុវត្តសិទ្ធអំណាចរដ្ឋ រួមចំណែកបង្កើតប្រព័ន្ធចាត់តាំងរដ្ឋ ដើម្បីអនុវត្តនូវសកម្មភាពគ្រប់គ្រងសង្គម។ ព្រោះហេតុនោះ អនុវត្តការបោះឆ្នោតគឺជាកាតព្វកិច្ចរបស់ពលរដ្ឋចំពោះប្រទេសជាតិ។

**សំណួរ ៨៖** តើការបោះឆ្នោតតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជន ត្រូវបានដំណើរការតាមគោលការណ៍ណាខ្លះ?

**ចម្លើយ៖**

តាមសេចក្តីកំណត់ត្រង់មាត្រា ៧ របស់រដ្ឋធម្មនុញ្ញ និងមាត្រា ១ ច្បាប់ស្តីពីការបោះឆ្នោតតំណាងរដ្ឋសភានិងតំណាងក្រុមប្រឹក្សាប្រជាជន ការបោះឆ្នោតតំណាងរដ្ឋសភានិងតំណាងក្រុមប្រឹក្សាប្រជាជន ត្រូវបានដំណើរការតាមគោលការណ៍ដូចខាងក្រោម៖

- គោលការណ៍បោះឆ្នោតជាសកល;

- គោលការណ៍សមភាព;

- គោលការណ៍បោះឆ្នោតផ្ទាល់;

- គោលការណ៍បោះឆ្នោតសម្ងាត់។

**សំណួរ ៩៖** គោលការណ៍សកលក្នុងការបោះឆ្នោតតើដូចម្តេច? (ពលរដ្ឋគ្រប់រូបដែលគ្រប់លក្ខខ័ណ្ឌ សុទ្ធតែមានសិទ្ធិបោះឆ្នោត មិនបែងចែកជនជាតិហ្វា ខ្មែរ ឬកិញ...)

**ចម្លើយ៖**

គោលការណ៍បោះឆ្នោតសកល ជាគោលការណ៍មួយក្នុងចំណោមគោលការណ៍មូលដ្ឋានរបស់របបបោះឆ្នោត។ យោងតាមគោលការណ៍នេះ ពលរដ្ឋគ្រប់រូប មិនបែងចែកជនជាតិ ភេទ ឋានៈសង្គម ជំនឿសាសនា កម្រិតវប្បធម៌ ឬមុខរបរនោះទេ ឱ្យតែមានអាយុគ្រប់ ១៨ ឆ្នាំឡើងទៅ សុទ្ធតែមានសិទ្ធិបោះឆ្នោត និងមានអាយុគ្រប់ ២១ ឆ្នាំឡើងទៅមានសិទ្ធិឈរឈ្មោះតំណាងរដ្ឋសភា តំណាងក្រុមប្រឹក្សាប្រជាជន តាមសេចក្តីកំណត់របស់ច្បាប់ (លើកលែងតែអ្នករងការដកហូតសិទ្ធិបោះឆ្នោតតាមសាលក្រម ឬសេចក្តីសម្រេចរបស់តុលាការ ដែលមានសុពលភាពតាមផ្លូវច្បាប់ ឬអ្នកដែលកាត់ទោសប្រហារជីវិតកំពុងរង់ចាំអនុវត្តសាលក្រម អ្នកកំពុងជាប់ពន្ធនាគារមិនបានទទួលការព្យួរទោស និងអ្នកមិនទៅសមត្ថភាពទង្វើរដ្ឋប្បវេណី)។ គោលការណ៍នេះ បង្ហាញពីតម្លាភាព ប្រជាធិបតេយ្យទូលំទូលាយ ធានាពលរដ្ឋអាចអនុវត្តសិទ្ធិបោះឆ្នោតនិងឈរឈ្មោះរបស់ខ្លួន។

**សំណួរ១០៖** តើដូចម្តេចជាគោលការណ៍សមភាពក្នុងការបោះឆ្នោត? (មនុស្សម្នាក់ៗមួយសន្លឹកឆ្នោតមានតម្លៃស្មើគ្នា)

**ចម្លើយ៖**

សមភាព គឺជាគោលការណ៍មួយក្នុងចំណោមគោលការណ៍សំខាន់ៗ ក្នុងពេលដំណើរការបោះឆ្នោត ចាប់ពីបង្កើតបញ្ជីឈ្មោះអ្នកបោះឆ្នោត រហូតដល់ការកំណត់លទ្ធផលបោះឆ្នោត គោលការណ៍នេះ ដើម្បីធានាសត្យានុម័ត មិនលំអៀង ដើម្បីពលរដ្ឋគ្រប់រូបមានសិទ្ធិស្មើគ្នាក្នុងការចូលរួមបោះឆ្នោតនិងឈរឈ្មោះ; ហាមដាច់ខាតរាល់ការបែងចែក រើសអើង ទោះជារូបភាពណាក៏ដោយ។ គោលការណ៍សមភាពក្នុងការបោះឆ្នោត ត្រូវបានបង្ហាញដូចខាងក្រោម៖

- ពលរដ្ឋម្នាក់ៗ អាចចុះឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតតែមួយប៉ុណ្ណោះ នៅកន្លែងដែលខ្លួនស្នាក់នៅ;

- មនុស្សម្នាក់ៗអាចចុះឈ្មោះក្នុងបញ្ជីអ្នកឈរឈ្មោះ នៅអង្គភាពបោះឆ្នោតតំណាងរដ្ឋសភា ០១ ឬអង្គភាពបោះឆ្នោតតំណាងក្រុមប្រឹក្សាប្រជាជន ០១ ចំណុះអង្គភាពរដ្ឋបាលមួយនៅថ្នាក់ប្រហាក់ប្រហែលគ្នា។

- អ្នកបោះឆ្នោតម្នាក់ៗបានបោះឆ្នោតតំណាងរាស្ត្រសភាមួយសន្លឹក និងតំណាងក្រុមប្រឹក្សាប្រជាជនថ្នាក់នីមួយៗមួយសន្លឹក;

- តម្លៃសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតម្នាក់ៗដូចគ្នា គ្មានការបែងចែក។

គោលការណ៍សមភាព ទាមទារមានការបែងចែកឱ្យបានសមស្របអំពីរចនាសម្ព័ន្ធ សមាសភាព និងចំនួនអ្នកបានឧទ្ទេសនាមឈរឆ្នោតតំណាងរាស្ត្រសភា តំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ និងចំនួនអ្នកតំណាងបានបោះឆ្នោតនៅតាមភូមិភាគនីមួយៗ ធានាប្រកបដោយលក្ខណៈតំណាងរបស់តំបន់ភូមិភាគនីមួយៗ និងស្រទាប់វណ្ណៈសង្គម; ជនជាតិភាគតិចនិងស្ត្រីមានអត្រាតំណាងសមស្របនៅក្នុងរដ្ឋ សភានិងក្រុមប្រឹក្សាប្រជាជន។

**សំណួរ ១១៖** តើដូចម្តេចជាគោលការណ៍បោះឆ្នោតផ្ទាល់?

**ចម្លើយ៖**

ការបោះឆ្នោតផ្ទាល់ គឺជាអ្នកបោះឆ្នោតត្រូវទៅបោះដោយផ្ទាល់ បោះសន្លឹកឆ្នោតរបស់ខ្លួនចូលក្នុងហិបឆ្នោត (ធុងឆ្នោត) ដើម្បីជ្រើសរើសអ្នកដែលទុកចិត្តចូលក្នុងស្ថាប័នអំណាចរដ្ឋ។ មាត្រា ៦៩ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសភានិងតំណាងក្រុមប្រឹក្សាប្រជាជនបានចែង៖ អ្នកបោះឆ្នោតមិនត្រូវពឹងអ្នកដទៃទៅបោះឆ្នោតជំនួស ឬបោះឆ្នោតដោយរបៀបផ្ញើសំបុត្រទេ។ ករណីអ្នកបោះឆ្នោតមិនអាចសរសេរសន្លឹកឆ្នោតដោយខ្លួនឯងបាន អាចពឹងអ្នកដទៃសរសេរជំនួស ប៉ុន្តែត្រូវតែបោះឆ្នោតដោយខ្លួនឯង; អ្នកសរសេរសន្លឹកឆ្នោតជំនួសត្រូវធានាសម្ងាត់របស់អ្នកបោះឆ្នោត។ ក្នុងករណីអ្នកបោះឆ្នោតពិការ មិនអាចបោះឆ្នោតដោយខ្លួនឯងបាន អាចពឹងអ្នកដទៃបោះសន្លឹកឆ្នោតចូលក្នុងហិបឆ្នោត។

ក្នុងករណីអ្នកបោះឆ្នោតមានជំងឺ ចាស់ជរា ឬពិការ មិនអាចទៅការិយាល័យបោះឆ្នោតបាន គណៈកម្មការរៀបចំការបោះឆ្នោតនឹងនាំហិបឆ្នោតផ្សេង និងសន្លឹកឆ្នោតទៅកាន់កន្លែងស្នាក់នៅ ឬកន្លែងព្យាបាលរបស់អ្នកបោះឆ្នោត ដើម្បីឱ្យអ្នកបោះឆ្នោតទទួលសន្លឹកឆ្នោតនិងបោះឆ្នោត។ ចំពោះអ្នកបោះឆ្នោតកំពុងជាប់ឃុំឃាំងបណ្តោះអាសន្ន អ្នកកំពុងអនុវត្តវិធានការចូលមូលដ្ឋានអប់រំចាប់បង្ខំ មូលដ្ឋានផ្តាច់ញៀនចាប់បង្ខំ ដែលមន្ទីរឃុំឃាំងបណ្តោះអាសន្ន មូលដ្ឋានអប់រំចាប់បង្ខំ មូលដ្ឋានផ្តាច់ញៀនចាប់បង្ខំ មិនចាត់តាំងកន្លែងបោះឆ្នោតដោយឡែក ឬ

អ្នកបោះឆ្នោត កំពុងជាប់ឃុំឃាំងនៅមន្ទីរឃុំឃាំងបណ្ដោះអាសន្ន គណៈកម្មាធិការរៀបចំការបោះឆ្នោតនាំហិបឆ្នោត និងសន្លឹកឆ្នោតទៅកាន់មន្ទីរឃុំឃាំងបណ្ដោះអាសន្ន មូលដ្ឋានអប់រំចាប់បង្ខំ មូលដ្ឋានផ្ដាច់ញៀនបចាប់បង្ខំ ដើម្បីអ្នកបោះឆ្នោតទទួលសន្លឹកឆ្នោតនិងបោះឆ្នោត។

**សំណួរ១២៖** តើគោលការណ៍បោះឆ្នោតសម្ងាត់នោះដូចម្ដេច?

**ចម្លើយ៖**

គោលការណ៍បោះឆ្នោតសម្ងាត់ ធានាឱ្យអ្នកបោះឆ្នោតមានសេរីភាពក្នុងការជ្រើសរើសអ្នកដែលខ្លួនទុកចិត្ត ដោយមិនរងឥទ្ធិពលដោយលក្ខខណ្ឌនិងកត្តាខាងក្រៅ។ ដូច្នេះ អ្នកបោះឆ្នោតបោះឱ្យអ្នកណា និងមិនបោះឱ្យអ្នកណា ត្រូវបានធានារក្សាការសម្ងាត់។ អ្នកបោះឆ្នោតសរសេរសន្លឹកឆ្នោតនៅក្នុងតំបន់ដោយឡែក គ្មានអ្នកណាមើល រួមទាំងសមាជិកគណៈកម្មការរៀបចំការបោះឆ្នោត; គ្មាននរណាម្នាក់ដឹង និងជ្រៀតជ្រែកក្នុងការសរសេរសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតនោះទេ។ អ្នកបោះឆ្នោត បោះសន្លឹកឆ្នោតរបស់ខ្លួនដោយខ្លួនឯងទៅក្នុងហិបឆ្នោត។

## ជំពូកទី II - អ្នកឈរឆ្នោត អ្នកបោះឆ្នោត និងឃោសនាបោះឆ្នោត

**សំណួរ១៣៖** អ្នកឈរឆ្នោតតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជន តើគប្បីមានបទដ្ឋានអ្វីខ្លះ?

**ចម្លើយ៖**

អ្នកឈរឆ្នោតតំណាងរដ្ឋសភា តំណាងក្រុមប្រឹក្សាប្រជាជន ត្រូវឆ្លើយតបនឹងបទដ្ឋានរបស់អ្នកតំណាងរដ្ឋសភា បទដ្ឋានរបស់អ្នកតំណាងក្រុមប្រឹក្សាប្រជាជនបានកំណត់ត្រង់ច្បាប់ស្ដីពីការរៀបចំសភា និងច្បាប់ស្ដីពីការរៀបចំរដ្ឋាភិបាលភូមិភាគ។ តាមសេចក្ដីកំណត់របស់ច្បាប់ដែលបានរៀបរាប់ខាងលើ គឺតំណាងរដ្ឋសភា តំណាងក្រុមប្រឹក្សាប្រជាជន ត្រូវមានបទដ្ឋានដូចខាងក្រោម៖

- ស្មោះត្រង់ចំពោះមាតុភូមិ ប្រជាជន និងរដ្ឋធម្មនុញ្ញ; ខិតខំអនុវត្តដំណើរការផ្លាស់ថ្មី ដើម្បីទិសដៅប្រជាជនសម្បូររុងរឿង ប្រទេសជាតិរឹងមាំ ប្រជាធិបតេយ្យ សមភាព និងអារ្យធម៌;

- មានសញ្ជាតិមួយ គឺសញ្ជាតិវៀតណាម;

- មានចរិយាសម្បត្តិ សីលធម៌ល្អ ឧស្សាហ៍ព្យាយាម សន្សំសំចៃ ស្មោះត្រង់ មិនគិតប្រយោជន៍ស្ទួនតួ និងជាគំរូគោរពច្បាប់; មានភាពក្លាហាន ប្តូរផ្តាច់តស៊ូប្រឆាំងអំពើពុករលួយ ភាពខ្ជះខ្ជាយ ភាពក្រអឺតក្រទម អំណាចផ្តាច់ការ និងទង្វើ ល្មើសច្បាប់ផ្សេងៗទៀត;

- មានកម្រិតវិជ្ជាឯកទេស មានសមត្ថភាពគ្រប់គ្រាន់ សុខភាព បទពិសោធន៍ការងារ និងមានប្រិយភាពដើម្បីអនុវត្តភារកិច្ច;

- មានទំនាក់ទំនងស្អិតល្មួតជាមួយប្រជាជន ស្តាប់មតិយោបល់របស់ប្រជាជន ហើយប្រជាជនជឿទុកចិត្ត;

- មានលក្ខណៈចូលរួមក្នុងសកម្មភាពរបស់រដ្ឋសភា និងសកម្មភាពរបស់ក្រុមប្រឹក្សាប្រជាជន;

អ្នកឈរឆ្នោត គឺអ្នកដែលបានឧទ្ទេសនាមឈរឆ្នោតតំណាងក្រុមប្រឹក្សាប្រជាជនរបស់ភូមិភាគណា គឺជាអ្នកកំពុងរស់នៅ ឬបំពេញការងារជាប្រចាំនៅភូមិភាគនោះ។

អ្នកបានឧទ្ទេសនាមឈរឆ្នោតតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់កំពុងបំពេញការងារនៅស្ថាប័នបក្ស រដ្ឋ រណសិរ្សមាតុភូមិវៀតណាម អង្គការនយោបាយ-សង្គម អង្គភាព បុព្វហេតុរដ្ឋការ ឬសហគ្រាសរដ្ឋ ត្រូវធានានូវបទដ្ឋានរួមតាមសេចក្តីកំណត់របស់បក្ស ច្បាប់របស់រដ្ឋ និងឆ្លើយតបបទដ្ឋានលក្ខណៈដូចខាងក្រោម៖

(១) ជាកម្មាភិបាល អ្នករដ្ឋការ បុគ្គលិកគំរូ;

(២) មានប្រិយភាព សមត្ថភាពក្នុងការអនុវត្ត និងឃោសនា ចលនាមហាជនប្រជាជនអនុវត្តបានល្អនូវគោលការណ៍ គោលនយោបាយរបស់បក្ស ច្បាប់របស់រដ្ឋយ៉ាងមានប្រសិទ្ធភាព;

(៣) មានឧត្តមគតិ សមត្ថភាពនយោបាយរឹងប៉ឹង ដាច់ខាត ស្មោះត្រង់ជាមួយផលប្រយោជន៍របស់បក្ស របស់រដ្ឋ និងរបស់ប្រជាជន; ប្តូរផ្តាច់តស៊ូការពារខឿនឧត្តមគតិរបស់បក្សរដ្ឋធម្មនុញ្ញ និងច្បាប់របស់រដ្ឋ;

(៤) មានចរិយាសម្បត្តិ សីលធម៌ ផ្ទត់រស់នៅជាគំរូ ស្មោះត្រង់; អនុវត្តម៉ឺងម៉ាត់នូវសេចក្តីកំណត់របស់បក្ស ច្បាប់របស់រដ្ឋ គោលការណ៍ប្រមូលផ្តុំប្រជាធិបតេយ្យ ទិតៀននិងស្វ័យ

ទិតៀន; មានស្មារតីពិន័យ និងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការងារ រក្សាសាមគ្គីភាពផ្ទៃក្នុង; ឧស្សាហ៍ព្យាយាម សន្សំសំចៃ ស្មោះត្រង់ និងមិនគិតប្រយោជន៍ស្ងួនតួ; ប្រកាសទ្រព្យសម្បត្តិ ប្រាក់ចំណូលដោយស្មោះត្រង់ តម្លាភាព មិនឱកាសនិយម មហិច្ឆិតាអំណាច អគតិ បក្សពួក អំពើពុករលួយ ភាពខ្ជះខ្ជាយ អវិជ្ជមាន ឬ"ផលប្រយោជន៍ក្រុម" មិនអនុញ្ញាតឱ្យប្ដីប្រពន្ធ កូន ឬសាច់ញាតិ ឆ្លៀតឱកាសតំណែងនិងអំណាច ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន;

(៥) មានសមត្ថភាពធ្វើឱ្យទៅជាភាពជាក់ស្ដែង និងចាត់តាំងអនុវត្តមានប្រសិទ្ធភាពនូវគោលការណ៍ គោលមាគ៌ារបស់បក្ស គោលនយោបាយនិងច្បាប់របស់រដ្ឋ; មានគំនិតផ្លាស់ថ្មី ចក្ខុវិស័យនិងវិធីសាស្ត្រធ្វើការវិទ្យាសាស្ត្រ; មានសមត្ថភាពត្រិះរិះ វិភាគ បូកសរុបនិងស្នើកសាងគោលនយោបាយ ច្បាប់ ដែលអាចធ្វើទៅបាននិងមានប្រសិទ្ធភាព; ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់នៅ ភូមិភាគ អង្គភាព និងកន្លែងឈរឈ្មោតតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជន; និយាយទន្ទឹមនឹងធ្វើ មានគំនិតច្នៃប្រតិដ្ឋ ហ៊ានគិត ហ៊ាននិយាយ ហ៊ានធ្វើ ហ៊ានទទួលខុសត្រូវ ហ៊ានប្រឈមមុខនឹងការលំបាកសាកល្បង ហ៊ានលះបង់ដើម្បីប្រយោជន៍រួម ដើម្បីប្រទេសជាតិ ដើម្បីប្រជាជន; មានស្នាដៃលទ្ធផលការងារ និង "ផលិតផល" ជាក់ស្ដែងលើភូមិដ្ឋាននិងវិស័យការងារបានប្រគល់;

(៦) មានកម្រិតវិជ្ជាឯកទេស ទ្រឹស្ដីនយោបាយ អភិបាលកិច្ច ឆ្លើយតបនឹងតម្រូវការភារកិច្ចដែលបានប្រគល់ និងតាមសេចក្ដីកំណត់របស់បក្សនិងរដ្ឋ; មានកម្រិតវិជ្ជាជំនាញព័ត៌មានវិទ្យា ភាសាបរទេស ចាំបាច់និងសមស្រប។

មិនឧទ្ទេសនាមបញ្ចូលក្នុងបញ្ជីអ្នកឈរឈ្មោត គឺអ្នកមានអាការៈឆ្លៀតឱកាសនយោបាយ មហិច្ឆិតាអំណាច; មានទស្សនៈប្រកាន់និយម អភិរក្សនិយម ភាពយឺតយ៉ាវ; កំពុងស្ថិតក្រោមការស៊ើបអង្កេត ត្រួតពិនិត្យ សវនកម្ម ត្រួតពិនិត្យពេលមានអាការៈបំពាន; ប្រធានស្ថាប័ន អង្គការ អង្គភាពដែលទុកឱ្យកើតឡើងរឿងក្ដី ករណីអំពើពុករលួយ ភាពខ្ជះខ្ជាយ អវិជ្ជមាន បែកបាក់សាមគ្គី។ កម្មាភិបាលមានការប្រព្រឹត្តល្មើស គុណវិបត្តិ ឬរងការដាក់ពិន័យក្នុងអាណត្តិកាល ២០២១ - ២០២៦; កម្មាភិបាលមានសាច់ញាតិល្មើសច្បាប់ អនុវត្តតាមសេចក្ដីសន្និដ្ឋាន លេខ ១៦៥-KL/TW ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០២៥ របស់ការិយាល័យនយោបាយ ស្ដីពីការតម្រង់ទិសអនុវត្តកិច្ចការកម្មាភិបាល ចំពោះកម្មាភិបាលល្មើសច្បាប់។ ករណីបំពានបទដ្ឋាន

នយោបាយ អនុវត្តតាមសេចក្ដីកំណត់របស់ការិយាល័យនយោបាយ អំពីបញ្ហាមួយចំនួនទាក់ទងដល់ការការពារនយោបាយផ្ទៃក្នុងរបស់បក្ស។ ប្ដេជ្ញាមិនទុកឱ្យអ្នកដែលមិនស័ក្ដិសម អ្នករត់រកតំណែងនិងអំណាចឈរឆ្នោតក្នុងរដ្ឋសភា និងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់។

យកចិត្តទុកដាក់ ឧទ្ទេសនាមអ្នកជំនាញឈានមុខគេលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យាផ្លាស់ថ្មីច្នៃប្រតិដ្ឋ ផ្លាស់ប្ដូរឌីជីថល និងឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់; អ្នកពូកែផ្នែកច្បាប់ មានប្រិយភាព យល់ដឹងជ្រៅជ្រះអំពីច្បាប់អន្តរជាតិ និងសហគ្រិនឆ្នើម ប្ដេជ្ញាជាមួយនឹងបុព្វហេតុបដិវត្តន៍របស់បក្សនិងប្រជាជន។

ក្រៅពីបទដ្ឋានរួមដែលបានរៀបរាប់ខាងលើ អ្នកដែលបានឧទ្ទេសនាមឈរឆ្នោតធ្វើជាតំណាងរដ្ឋសភាបំពេញភារកិច្ចជំនាញពិសេស តំណាងក្រុមប្រឹក្សាប្រជាជនបំពេញភារកិច្ចជំនាញពិសេស ថែមទាំងឆ្លើយតបនឹងបទដ្ឋានខ្ពស់មួយចំនួន អំពីកម្រិតវិជ្ជាឯកទេស មុខតំណែងការងារកំពុងទទួលបន្ទុក អំពីស្ថានភាពសុខភាព និងកម្រិតអាយុអ្នកឈរឆ្នោតឬឈរឆ្នោតឡើងវិញ (លើកឡើងជាក់ស្ដែងត្រង់សេចក្ដីណែនាំលេខ ៣៦-HD/BTCTW ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០២៥ របស់គណៈចាត់តាំងមជ្ឈិម)។

**សំណួរ ១៤៖** តើអ្នកណាខ្លះបានហៅថា អ្នកបោះឆ្នោត?

**ចម្លើយ៖**

អ្នកបោះឆ្នោត គឺជាអ្នកមានសិទ្ធិបោះឆ្នោត។ ពលរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម - ជាអ្នកមានសញ្ជាតិវៀតណាម គិតដល់ថ្ងៃបោះឆ្នោត (១៥/៣/២០២៦) មានអាយុគ្រប់ ១៨ឆ្នាំឡើង និងគ្រប់លក្ខខ័ណ្ឌតាមសេចក្ដីកំណត់របស់ច្បាប់បោះឆ្នោត សុទ្ធតែមានសិទ្ធិបោះឆ្នោត។

**សំណួរ ១៥៖** ការបង្កើតបញ្ជីឈ្មោះអ្នកបោះឆ្នោត និងបិទប្រកាសបញ្ជីឈ្មោះអ្នកបោះឆ្នោត តើបានដំណើរការយ៉ាងដូចម្ដេច?

**ចម្លើយ៖**

បញ្ជីឈ្មោះអ្នកបោះឆ្នោត អាស្រ័យគណៈកម្មាធិការប្រជាជនថ្នាក់ឃុំបង្កើតឡើងទៅតាមមណ្ឌលបោះឆ្នោតនីមួយៗ។ បញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងអង្គភាពកងកម្លាំងប្រដាប់

អាវុធប្រជាជន អាស្រ័យបញ្ជាការអង្គភាពបង្កើតឡើង តាមអង្គភាពកងកម្លាំងប្រដាប់អាវុធប្រជាជន ដើម្បីបញ្ចូលក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតរបស់មណ្ឌលបោះឆ្នោត ទីតាំងដែលអង្គភាពបោះទ័ព។

ពលរដ្ឋគ្រប់រូបមានសិទ្ធិបោះឆ្នោត សុទ្ធតែបានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងបាន ចេញប័ណ្ណអ្នកបោះឆ្នោតសម្រាប់បោះឆ្នោតតំណាង នីតិកាលទី១៦ និងបោះឆ្នោតតំណាងក្រុមប្រឹក្សា ប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦-២០៣១ លើកលែងតែអ្នករងការដកហូតសិទ្ធិបោះឆ្នោតតាមសាលក្រម ឬសេចក្តីសម្រេចរបស់តុលាការដែលមានសុពលភាពតាមផ្លូវច្បាប់ ឬអ្នកដែលកាត់ទោសប្រហារជីវិតកំពុងរង់ចាំអនុវត្តសាលក្រម អ្នកកំពុងជាប់ពន្ធនាគារដោយមិនបានទទួលការព្យួរទោស និងអ្នកមិននៅសមត្ថភាពសកម្មភាពផ្លូវច្បាប់។

ពលរដ្ឋម្នាក់ៗ អាចចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតតែមួយប៉ុណ្ណោះ នៅកន្លែងស្នាក់នៅអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន។ គណៈកម្មាធិការប្រជាជនថ្នាក់ឃុំ ទទួលខុសត្រូវក្នុងការជូនដំណឹងដល់អ្នកបោះឆ្នោតនៅភូមិភាគ អំពីការបង្កើតបញ្ជីឈ្មោះអ្នកបោះឆ្នោតទៅតាមមណ្ឌលបោះឆ្នោតនីមួយៗ។ អ្នកបោះឆ្នោតដែលបានចុះឈ្មោះរស់នៅអចិន្ត្រៃយ៍លើភូមិដ្ឋាន បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅកន្លែងស្នាក់នៅអចិន្ត្រៃយ៍; ករណីអ្នកបោះឆ្នោតចង់បោះឆ្នោតនៅកន្លែងផ្សេង ត្រូវជូនដំណឹងដល់គណៈកម្មាធិការប្រជាជននៅថ្នាក់ឃុំ មិនចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅភូមិភាគ។ ក្នុងដំណើរការបង្កើតបញ្ជីឈ្មោះអ្នកបោះឆ្នោត គណៈកម្មាធិការប្រជាជនថ្នាក់ឃុំគ្រាន់តែបញ្ចូលក្នុងបញ្ជីអ្នក បោះឆ្នោតកំពុងចុះឈ្មោះស្នាក់នៅបណ្តោះអាសន្ននៅភូមិភាគ បើអ្នកបោះឆ្នោតនោះបង្ហាញច្បាស់ពីបំណងចង់បានចូលរួមបោះឆ្នោតនៅកន្លែងស្នាក់នៅបណ្តោះអាសន្ន (អាចលាយលក្ខណ៍ជាអក្សរ ឬនិយាយផ្ទាល់មាត់ដល់អ្នកទទួលខុសត្រូវ តួយ៉ាងដូចប្រធានភូមិ ប្រធានក្រុមប្រជាជនក្រុងឬកម្មាភិបាល ទទួលបន្ទុកការងារបង្កើតបញ្ជីឈ្មោះអ្នកបោះឆ្នោតរបស់គណៈកម្មាធិការប្រជាជនថ្នាក់ឃុំ...)។

យឺតបំផុតគឺថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៦ (មុនថ្ងៃបោះឆ្នោត៤០ថ្ងៃ) គណៈកម្មាធិការប្រជាជនថ្នាក់ឃុំបង្កើតបញ្ជីឈ្មោះអ្នកបោះឆ្នោត ត្រូវតែបិទប្រកាសបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅទីស្នាក់ការគណៈកម្មាធិការប្រជាជនឃុំ និងនៅកន្លែងសាធារណៈនៃមណ្ឌលបោះឆ្នោត ទន្ទឹមនឹង

នោះ ជូនដំណឹងឱ្យទូលំទូលាយអំពីបញ្ជីឈ្មោះអ្នកបោះឆ្នោត និងការបិទប្រកាសដើម្បីប្រជាជនពិនិត្យមើល។

ការបង្កើត បិទប្រកាសបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងការផ្លាស់ប្ដូរបន្ថែម និងអាប់ដេតបញ្ជីឈ្មោះអ្នកបោះឆ្នោត ត្រូវបានអនុវត្តតាមសេចក្តីកំណត់របស់ច្បាប់ស្តីពីការបោះឆ្នោតតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជន សារាចរលេខ ២១/២០២៥/TT-BNV ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៥ របស់ក្រសួងមហាផ្ទៃ និងសេចក្តីសម្រេចលេខ ៨២០២/QĐ-BCA-C06 ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ ២០២៥ របស់ក្រសួងនគរបាល។

**សំណួរ ១៦៖** តើអ្នកណាខ្លះមិនបានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត?

**ចម្លើយ៖**

អ្នកដែលស្ថិតក្នុងករណីដូចខាងក្រោម មិនបានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត៖

- អ្នករងការដកហូតសិទ្ធិបោះឆ្នោតតាមសាលក្រម ឬសេចក្តីសម្រេចរបស់តុលាការដែលមានសុពលភាពតាមផ្លូវច្បាប់;

- អ្នកដែលកាត់ទោសប្រហារជីវិតកំពុងរង់ចាំអនុវត្តសាលក្រម;

- អ្នកកំពុងជាប់ពន្ធនាគារដោយមិនបានទទួលការព្យួរទោស;

- អ្នកបាត់បង់សមត្ថភាពសកម្មភាពផ្លូវច្បាប់។

**សំណួរ ១៧៖** ក្នុងករណីណាខ្លះដែលអ្នកបោះឆ្នោត បានចូលរួមបោះឆ្នោតតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជនថ្នាក់ខេត្តនិងថ្នាក់ឃុំ?

**ចម្លើយ៖**

អ្នកបោះឆ្នោតបានចូលរួមបោះឆ្នោតតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជនថ្នាក់ខេត្តនិងឃុំ ក្នុងករណីដូចខាងក្រោម៖

- អ្នកបោះឆ្នោតជាអ្នករស់នៅអចិន្ត្រៃយ៍នៅអង្គភាពរដ្ឋបាលថ្នាក់ឃុំ;

- អ្នកបោះឆ្នោតជាអ្នករស់នៅបណ្តោះអាសន្ននៅអង្គភាពរដ្ឋបាលថ្នាក់ឃុំ និងមានរយៈពេលចុះឈ្មោះស្នាក់នៅបណ្តោះអាសន្នគ្រប់ ១២ ខែឡើងទៅ;

- ពលរដ្ឋវៀតណាមដែលរស់នៅបរទេស វិលត្រឡប់មកប្រទេសវៀតណាមវិញ ក្នុងអំឡុងពេលក្រោយពីបញ្ជីឈ្មោះអ្នកបោះឆ្នោតបានបិទប្រកាស រហូតដល់មុនពេលចាប់ផ្តើមបោះឆ្នោត ២៤ ម៉ោង បានធ្វើបែបបទចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅកន្លែងស្នាក់នៅអចិន្ត្រៃយ៍;

- អ្នកកំពុងជាប់ឃុំបណ្តោះអាសន្ន អ្នកដែលកំពុងអនុវត្តវិធានការបញ្ជូនចូលមូលដ្ឋានអប់រំចាប់បង្ខំ មូលដ្ឋានផ្តាច់ញៀនចាប់បង្ខំ ប្រសិនមកដល់មុនការចាប់ផ្តើមនៃការបោះឆ្នោះ ២៤ ម៉ោង ហើយត្រូវបានដោះលែង ឬបញ្ចប់ពេលវេលាអប់រំចាប់បង្ខំ ផ្តាច់ញៀនចាប់បង្ខំ ហើយបានធ្វើបែបបទដើម្បីលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត នៅមន្ទីរឃុំឃាំងបណ្តោះអាសន្ន មូលដ្ឋានអប់រំជាចាប់បង្ខំ មូលដ្ឋានផ្តាច់ញៀនចាប់បង្ខំ និងបានបន្ថែមទៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅកន្លែងស្នាក់នៅអចិន្ត្រៃយ៍របស់ពួកគេ។

**សំណួរ ១៨.** តើការឃោសនាបោះឆ្នោតមានន័យដូចម្តេច ត្រូវធានាតាមលក្ខខ័ណ្ឌអ្វីខ្លះ?

**ចម្លើយ៖**

ការឃោសនាបោះឆ្នោតរបស់បេក្ខជនឈរឆ្នោត គឺជាសកម្មភាពជួបជុំនិងទំនាក់ទំនងជាមួយអ្នកបោះឆ្នោត ឬធ្វើតាមរយៈមធ្យោបាយព័ត៌មានសាធារណៈ ដើម្បីឱ្យបេក្ខជនឈរឈ្មោះតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជន រាយការណ៍ជូនអ្នកបោះឆ្នោតអំពីកម្មវិធីសកម្មភាពដែលគ្រោង អនុវត្តរបស់ខ្លួន ដើម្បីបំពេញភារកិច្ចជាអ្នកតំណាង ប្រសិនបើត្រូវបានបោះឆ្នោតជាតំណាងរដ្ឋសភា ឬតំណាងក្រុមប្រឹក្សាប្រជាជន។ និងធ្វើការផ្លាស់ប្តូរអំពីបញ្ហាដែលអ្នកបោះឆ្នោតកំពុងយកចិត្តទុកដាក់ផងដែរ; បង្កលក្ខណៈឱ្យអ្នកបោះឆ្នោត បានជួបនិងស្គាល់អ្នកឈរឈ្មោះឱ្យច្បាស់ជាងមុន។ ផ្អែកលើមូលដ្ឋាននោះ អ្នកបោះឆ្នោតអាចពិចារណាជ្រើសរើស និងបោះឆ្នោតឱ្យបុគ្គលដែលមានគុណសម្បត្តិគ្រប់គ្រាន់ ធ្វើជាតំណាងរដ្ឋសភានិងតំណាងក្រុមប្រឹក្សាប្រជាជន។

ការរៀបចំការឃោសនាបោះឆ្នោត ត្រូវធានាតាមលក្ខខ័ណ្ឌដូចខាងក្រោម៖

- ការឃោសនាបោះឆ្នោត ត្រូវអនុវត្តដោយមានលក្ខណៈប្រជាធិបតេយ្យ បើកចំហ សមភាព ស្របតាមច្បាប់ ធានារក្សាសណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម;

- បេក្ខជនឈរឈ្មោះជាតំណាងរដ្ឋសភា ឬបេក្ខជនឈរឈ្មោះជាតំណាងក្រុមប្រឹក្សាប្រជាជននៅមណ្ឌលបោះឆ្នោតណា ត្រូវអនុវត្តការឃោសនាបោះឆ្នោតនៅមណ្ឌលបោះឆ្នោតនោះ;

- អង្គការដែលទទួលខុសត្រូវរៀបចំការបោះឆ្នោត និងសមាជិកនៃអង្គការទាំងនេះ មិនត្រូវ

ធ្វើការឃោសនាសម្រាប់បេក្ខជនរូបណាមួយឡើយ។

**សំណួរ ១៩.** តើបេក្ខជនឈរឈ្មោះ អាចប្រើប្រាស់របៀបណាខ្លះក្នុងការឃោសនាបោះឆ្នោត?

**ចម្លើយ៖**

ការឃោសនាបោះឆ្នោតរបស់បេក្ខជនឈរឈ្មោះ ត្រូវអនុវត្តតាមរបៀបដូចខាងក្រោម៖

- ការជួបជុំនិងទំនាក់ទំនងជាមួយអ្នកបោះឆ្នោត នៅក្នុងកិច្ចប្រជុំជួបអ្នកបោះឆ្នោតនៅតំបន់ដែលខ្លួនឈរឈ្មោះជាបេក្ខជន;
- ធ្វើតាមរយៈមធ្យោបាយព័ត៌មានសាធារណៈ។

**សំណួរ ២០.** ក្នុងការឃោសនាបោះឆ្នោត ច្បាប់ហាមឃាត់សកម្មភាពណាខ្លះ?

**ចម្លើយ៖**

សកម្មភាពដែលត្រូវបានហាមឃាត់ក្នុងការឃោសនាបោះឆ្នោត រួមមាន៖

- ប្រើប្រាស់ការឃោសនាបោះឆ្នោត ដើម្បីផ្សព្វផ្សាយអ្វីដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញនិងច្បាប់ ឬធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ កេរ្តិ៍ឈ្មោះ សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ផ្សេងៗរបស់អង្គការ ឬបុគ្គលផ្សេងទៀត;

- ឆ្លៀតប្រើអំណាច ឬតួនាទីដោយមិនត្រឹមត្រូវ ដើម្បីប្រើប្រាស់មធ្យោបាយព័ត៌មានសាធារណៈក្នុងការឃោសនាបោះឆ្នោត;

- ប្រើប្រាស់ការឃោសនាបោះឆ្នោត ដើម្បីអំពាវនាវឱ្យមានការឧបត្ថម្ភ ឬប្រមូលថវិកាពីក្នុងប្រទេសនិងក្រៅប្រទេសសម្រាប់អង្គការ ឬបុគ្គលឯកជន។

- ប្រើប្រាស់ ឬសន្យាផ្តល់ អំណោយ ឧបត្ថម្ភប្រាក់ ទ្រព្យសម្បត្តិ ឬផលប្រយោជន៍សម្ភារៈ ដើម្បីទាក់ទាញ ឬទិញទឹកចិត្តម្ចាស់ឆ្នោត;

- ក្រុមប្រឹក្សាបោះឆ្នោតជាតិ គណៈកម្មាធិការបោះឆ្នោត គណៈកម្មការបោះឆ្នោតនិង ក្រុមការងារបោះឆ្នោត មិនត្រូវធ្វើការឃោសនាសម្រាប់បេក្ខជនណាមួយឡើយ។ សមាជិកនៃអង្គការទទួលបន្ទុកការបោះឆ្នោតដែលបានរៀបរាប់ខាងលើ មិនត្រូវប្រើប្រាស់តួនាទីឬអំណាចរបស់ខ្លួន ដើម្បីធ្វើការឃោសនាសម្រាប់បេក្ខជនណាមួយ ដើម្បីធានាយុត្តិធម៌និងស្មើភាពចំពោះបេក្ខជនទាំងអស់។

**ជំពូកទី III - ថ្ងៃបោះឆ្នោត គោលការណ៍និងរបៀបនៃការបោះឆ្នោត; ភារកិច្ចរបស់ពលរដ្ឋ**

**សំណួរ ២១.** តើថ្ងៃបោះឆ្នោតត្រូវបានកំណត់យ៉ាងដូចម្ដេច ?

**ចម្លើយ៖**

ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជនកំណត់ថា ថ្ងៃបោះឆ្នោតត្រូវតែជាថ្ងៃអាទិត្យ ហើយត្រូវប្រកាសយ៉ាងយឺតបំផុត ១១៥ ថ្ងៃ មុនថ្ងៃបោះឆ្នោត។ ចំពោះករណីពិសេសដែលត្រូវពន្យារថ្ងៃបោះឆ្នោត ឬបោះឆ្នោតមុនថ្ងៃដែលបានកំណត់ គណៈកម្មាធិការបោះឆ្នោត ត្រូវដាក់សំណើទៅក្រុមប្រឹក្សាបោះឆ្នោតជាតិ ដើម្បីពិនិត្យសម្រេច។

ដោយផ្អែកលើបទប្បញ្ញត្តិដែលបាននិយាយខាងលើ រដ្ឋសភាវៀតណាម នីតិកាលទី ១៥ បានចេញសេចក្ដីសម្រេចលេខ ១៩៩/២២៥/QH១៥ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ដែលកំណត់ច្បាស់ថា ថ្ងៃបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា នីតិកាលទី ១៦ និងតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦-២០៣១ គឺជាថ្ងៃអាទិត្យ ទី១៥ ខែមីនា ឆ្នាំ២០២៦។

**សំណួរ ២២.** តើពេលវេលានៃការបោះឆ្នោតនៅថ្ងៃបោះឆ្នោត ប្រព្រឹត្តទៅនៅពេលណា?

**ចម្លើយ៖**

ក្នុងថ្ងៃបោះឆ្នោតដែលត្រូវបានអង្គភាពមានសមត្ថកិច្ចសម្រេច និងប្រកាសការបោះឆ្នោតនឹងចាប់ផ្ដើមពីម៉ោង ០៧:00 ព្រឹក ហើយអនុវត្តជាបន្តបន្ទាប់រហូតដល់ម៉ោង ០៧:00 ល្ងាចនៃថ្ងៃដដែល។ អាស្រ័យលើស្ថានភាពរបស់មូលដ្ឋាន ក្រុមបោះឆ្នោតអាចសម្រេចឱ្យចាប់ផ្ដើមការបោះឆ្នោតមុនជាងនេះបាន ប៉ុន្តែមិនត្រូវមុនម៉ោង ០៥:00 ព្រឹក ឬបញ្ចប់យឺតជាងនេះបាន ប៉ុន្តែមិនត្រូវលើសម៉ោង ០៩:00 យប់ នៃថ្ងៃដដែលឡើយ។

ចំពោះករណីជិតដល់ម៉ោងបញ្ចប់ការបោះឆ្នោតតាមការកំណត់ ប៉ុន្តែនៅមានអ្នកបោះឆ្នោតមួយចំនួនមិនទាន់បញ្ចប់ការបោះឆ្នោត ក្រុមបោះឆ្នោតមានភារកិច្ចជូនដំណឹងដល់អ្នកបោះឆ្នោតដែលនៅក្នុងមណ្ឌលបន្ទប់បោះឆ្នោត អំពីការត្រៀមបញ្ចប់ពេលវេលានៃការបោះឆ្នោតនិងស្នើឱ្យអ្នកបោះឆ្នោត ប្រញាប់បញ្ចប់ការបោះឆ្នោតរបស់ខ្លួន។ ក្រុមបោះឆ្នោតត្រូវអនុវត្តការបិទហិបឆ្នោតតាមពេលវេលាដែលបានកំណត់ មិនអាស្រ័យលើថាអ្នកបោះឆ្នោត បានបោះឆ្នោតគ្រប់គ្នាហើយឬនៅនោះទេ។

ការបោះឆ្នោតត្រូវអនុវត្តជាបន្តបន្ទាប់។ ក្នុងករណីមានហេតុការណ៍កើតឡើងជាយថា

ហេតុ ដែលបង្កឱ្យការបោះឆ្នោតត្រូវផ្អាក ក្រុមបោះឆ្នោតត្រូវបិទហិបឆ្នោត និងឯកសារដែលពាក់ព័ន្ធដោយផ្ទាល់ នឹងការបោះឆ្នោតភ្លាមៗ ហើយរាយការណ៍បន្ទាន់ទៅកាន់គណៈកម្មការបោះឆ្នោត។ ព្រមទាំងត្រូវអនុវត្តវិធានការចាំបាច់ ដើម្បីឱ្យការបោះឆ្នោតអាចបន្តបានវិញ។

ក្នុងករណីដែលមិនទាន់ដល់ពេលបញ្ចប់ការបោះឆ្នោតតាមការកំណត់ ប៉ុន្តែមានអ្នកនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅមណ្ឌលបោះឆ្នោត បានចូលរួមបោះឆ្នោតគ្រប់ ១០០% រួចហើយក្រុមបោះ ឆ្នោតក៏មិនត្រូវប្រកាសបញ្ចប់ការបោះឆ្នោត និងមិនត្រូវធ្វើការរាប់សន្លឹកឆ្នោតមុនម៉ោង ០៧:០០ ល្ងាចនៃថ្ងៃដដែលឡើយ។ ដូច្នេះ តាមគោលការណ៍ ក្រុមបោះឆ្នោតនិងសមាជិកនៃក្រុមបោះឆ្នោត អាចធ្វើការអំពាវនាវ ឬផ្សព្វផ្សាយដើម្បីឱ្យអ្នកបោះឆ្នោតចូលរួមបោះឆ្នោតយ៉ាងសកម្ម និងអនុវត្តសិទ្ធិបោះឆ្នោរបស់ខ្លួន ប៉ុន្តែមិនត្រូវជំរុញ ឬបង្ខំឱ្យអ្នកបោះឆ្នោតទៅបោះឆ្នោតឱ្យលឿន ដើម្បីបញ្ចប់ការបោះឆ្នោតឱ្យឆាប់ឡើយ។

**សំណួរ ២៣**. នៅពេលមកដល់បន្ទប់បោះឆ្នោត តើអ្នកបោះឆ្នោតត្រូវអនុវត្តតាមបទប្បញ្ញត្តិអ្វីខ្លះ?

**ចម្លើយ៖**

ដើម្បីឱ្យការបោះឆ្នោតទទួលបានលទ្ធផលល្អ ធានាបានលក្ខណៈប្រជាធិបតេយ្យ ស្របច្បាប់ និងរក្សាសណ្ដាប់ធ្នាប់ សុវត្ថិភាព ជាពិសេសនៅថ្ងៃបោះឆ្នោត អង្គការដែលទទួលខុសត្រូវរៀបចំការបោះឆ្នោតនិងប្រជាជនគ្រប់រូប ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់តាមច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជន ព្រមទាំងឯកសារច្បាប់ ពាក់ព័ន្ធផ្សេងៗទៀត។ នៅពេលទៅបោះឆ្នោត ពលរដ្ឋគ្រប់រូបត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងនៃបន្ទប់បោះឆ្នោត ដែលកំណត់ដោយក្រុមប្រឹក្សាបោះឆ្នោតជាតិ។

បទបញ្ជាផ្ទៃក្នុងនៃបន្ទប់បោះឆ្នោត ត្រូវបានក្រុមបោះឆ្នោតបិទប្រកាសនៅបន្ទប់បោះឆ្នោត ហើយមានខ្លឹមសារដូចខាងក្រោម៖

- ត្រូវអនុវត្តតាមគោលការណ៍ និងលំដាប់លំដោយនៃការបោះឆ្នោតឱ្យបានត្រឹមត្រូវ;

- អ្នកបោះឆ្នោតត្រូវឈរជាជួរតាមលំដាប់ ដើម្បីអនុវត្តការបោះឆ្នោត ហើយផ្ដល់អាទិភាពដល់មនុស្សចាស់ អ្នកពិការ និងស្ត្រីមានផ្ទៃពោះ;

- ត្រូវរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ និងសុវត្ថិភាពនៅមណ្ឌលបោះឆ្នោត ហាមដាច់ខាតរាល់សកម្មភាពបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ ទ្រព្យសម្បត្តិ ឬបង្កភាពរញ៉េរញ៉ៃ នៅមណ្ឌលបោះឆ្នោតនិងបន្ទប់បោះឆ្នោត។

- មិនត្រូវធ្វើការឃោសនាបោះឆ្នោតនៅកន្លែងបោះឆ្នោត ដោយរូបភាពណាមួយឡើយ;

- មិនត្រូវយកអាវុធ សារធាតុផ្ទុះ វត្ថុងាយឆេះ ឯកសារ បដាឬពាក្យស្លោកដែលមានខ្លឹមសារមិនល្អ ពិសពុល ឬផ្សព្វផ្សាយមតិផ្ទុយ អរិភាព បំភាន់ឬបំភ្លៃគោលនយោបាយ ទិសដៅនិងគោលការណ៍របស់បក្ស រដ្ឋ និងរដ្ឋអំណាចមូលដ្ឋាន ។ល។ ចូលក្នុងមណ្ឌលបោះឆ្នោតនិងបន្ទប់បោះឆ្នោតឡើយ;

- អ្នកដែលមិនមានភារកិច្ច មិនត្រូវចូលទៅក្នុងបន្ទប់បោះឆ្នោតឡើយ។

- សមាជិករបស់អង្គការដែលទទួលបន្ទុកការបោះឆ្នោត និងអ្នកដែលមានភារកិច្ចបម្រើការងារបោះឆ្នោត ត្រូវពាក់សញ្ញាសម្គាល់តាមគំរូដែលកំណត់ដោយគណៈកម្មាធិការបោះឆ្នោតទីក្រុង; សមាជិកក្រុមបោះឆ្នោត មានភារកិច្ចណែនាំអ្នកបោះឆ្នោតក្នុងការបោះឆ្នោត និងឆ្លើយសំណួររបស់អ្នកបោះឆ្នោត;

- អ្នកណាដែលប្រើល្បិចបោកបញ្ឆោត ទិញទឹកចិត្តម្ចាស់ឆ្នោត បង្ខំ ឬរារាំងការបោះឆ្នោតរបស់ប្រជាជន បំពានបទប្បញ្ញត្តិស្តីពីការឃោសនាបោះឆ្នោត; អ្នកដែលមានភារកិច្ចក្នុងការងារបោះឆ្នោត បង្កើតឯកសារក្លែងក្លាយ ក្លែងបន្លំសន្លឹកឆ្នោត ឬប្រើវិធីផ្សេងៗដើម្បីបំភាន់លទ្ធផលបោះឆ្នោត ឬបំពានបទប្បញ្ញត្តិផ្សេងៗ នៃច្បាប់ស្តីពីការបោះឆ្នោត នឹងត្រូវដាក់ពិន័យ ផាកពិន័យរដ្ឋបាល ឬត្រូវស៊ើបអង្កេតទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ អាស្រ័យលើលក្ខណៈនិងកម្រិតនៃការបំពាន។

**សំណួរ ២៤.** តើការបោះឆ្នោតត្រូវអនុវត្តតាមគោលការណ៍អ្វីខ្លះ ?

**ចម្លើយ៖**

ច្បាប់ស្តីពីការបោះឆ្នោតតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជន កំណត់អំពីគោលការណ៍បោះឆ្នោតដូចខាងក្រោម៖

- អ្នកបោះឆ្នោតម្នាក់ៗ មានសិទ្ធិបោះមួយសន្លឹក សម្រាប់ជ្រើសរើសតំណាងរដ្ឋសភា និងបោះមួយសន្លឹក សម្រាប់ជ្រើសរើសតំណាងក្រុមប្រឹក្សាប្រជាជន ស្របតាមកម្រិតនីមួយៗនៃក្រុមប្រឹក្សាប្រជាជន;

- អ្នកបោះឆ្នោតត្រូវទៅបោះឆ្នោតដោយខ្លួនឯង មិនអាចឱ្យអ្នកផ្សេងបោះជំនួសបានទេ;

- នៅពេលអ្នកបោះឆ្នោតគូសសន្លឹកឆ្នោត មិនអនុញ្ញាតឱ្យនរណាម្នាក់មើលឡើយ សូម្បីសមាជិកក្រុមបោះឆ្នោត;

- ប្រសិនបើគូសខុស អ្នកបោះឆ្នោតមានសិទ្ធិប្តូរសន្លឹកឆ្នោតថ្មីបាន;

- បន្ទាប់ពីអ្នកបោះឆ្នោតបោះសន្លឹកឆ្នោតរួច ក្រុមបោះឆ្នោតមានភារកិច្ចបោះត្រា "បានបោះឆ្នោតរួច" លើប័ណ្ណអ្នកបោះឆ្នោត;

- ពលរដ្ឋគ្រប់រូបត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងនៃបន្ទប់បោះឆ្នោត។

**សំណួរ ២៥.** តើអ្នកបោះឆ្នោតត្រូវគូសសន្លឹកឆ្នោតយ៉ាងដូចម្តេច ដើម្បីឱ្យត្រឹមត្រូវ ?

**ចម្លើយ៖**

សមាជិកនៃក្រុមបោះឆ្នោត មានភារកិច្ចណែនាំយ៉ាងច្បាស់លាស់ដល់អ្នកបោះឆ្នោតអំពីរបៀបបោះឆ្នោត។ ប្រសិនបើអ្នកបោះឆ្នោតមិនទុកចិត្តលើបេក្ខជនណាម្នាក់ (មិនបោះឆ្នោតឱ្យបេក្ខជនដែលមានឈ្មោះក្នុងសន្លឹកឆ្នោត) ត្រូវគូសបន្ទាត់កាត់លើនាមត្រកូលនិងនាមរបស់បេក្ខជននោះ (គូសកាត់លើបន្ទាត់អក្សរដែលជានាមត្រកូល និងនាមរបស់បេក្ខជន)។ មិនត្រូវគូសរង្វង់ជុំវិញឈ្មោះ; មិនត្រូវគូសសញ្ញាណាមួយលើសន្លឹកឆ្នោត; មិនត្រូវសរសេរបន្ថែមឈ្មោះមនុស្សក្រៅបញ្ជីបេក្ខជនចូលក្នុងសន្លឹកឆ្នោត; មិនត្រូវបោះឆ្នោត ឬជ្រើសរើសលើសចំនួនតំណាងដែលបានកំណត់ក្នុងសន្លឹកឆ្នោត; មិនត្រូវគូសកាត់បេក្ខជនទាំងអស់នៅក្នុងសន្លឹកឆ្នោត; មិនត្រូវទុកសន្លឹកឆ្នោតដដែល (មិនគូសឈ្មោះបេក្ខជនណាម្នាក់ឡើយ) ចំពោះសន្លឹកឆ្នោតដែលមានចំនួនបេក្ខជនលើសពីចំនួនតំណាងដែលត្រូវជ្រើសរើស។

ក្នុងករណីសន្លឹកឆ្នោតមានការគូសកាត់ជាទម្រង់គូសខ្វែង គូសទ្រេត គូសបញ្ឈរ ឬគូសទទឹង ប៉ុន្តែបានគូសកាត់លើបន្ទាត់អក្សរនាមត្រកូល និងនាមទាំងមូលរបស់បេក្ខជន នោះត្រូវបានរាប់ថា ជាសន្លឹកឆ្នោតមិនបានបោះឱ្យបេក្ខជននោះ។

ក្នុងករណីអ្នកបោះឆ្នោត មិនបានគូសកាត់លើបន្ទាត់អក្សរនាមត្រកូល និងនាមទាំងមូល (គ្រាន់តែគូសតែនាមត្រកូល ឬគូសតែនាមកណ្តាល ឬនាម) ឬគ្រាន់តែគូសរង្វង់ គូសបន្ទាត់ក្រោមឬគូសបន្ទាត់ លើបន្ទាត់អក្សរនាមត្រកូល និងនាមរបស់បេក្ខជនសន្លឹកឆ្នោតនោះ នៅតែត្រូវបានគេចាត់ទុកថាបោះឱ្យបេក្ខជននោះ។

ករណីនៅក្នុងសន្លឹកឆ្នោត បេក្ខជនម្នាក់មានទាំងឈ្មោះកំណើត និងឈ្មោះហៅជាទូទៅ ឬមានតួនាទី នាមបញ្ញត្តិ ឬគោរម្យនាមតាមសាសនា ប្រសិនបើអ្នកបោះឆ្នោតគ្រាន់តែគូសកាត់តែមួយបន្ទាត់នៃនាមត្រកូល និងនាមកំណើតឬនាមត្រកូល និងឈ្មោះហៅជាទូទៅ (ឬគូសតែមួយបន្ទាត់នៃនាមត្រកូលនិងនាមកំណើត ឬតួនាទី នាមបញ្ញត្តិ ឬគោរម្យនាមតាមសាសនា ចំពោះបុគ្គលដែលមានឋានៈក្នុងសាសនា) គឺសន្លឹកឆ្នោតនោះ ត្រូវបានគេរាប់ថាជាសន្លឹកឆ្នោតមិនបោះឱ្យបេក្ខជននោះ។

ប្រសិនបើអ្នកបោះឆ្នោតស្នើសុំប្តូរសន្លឹកឆ្នោតថ្មី ដោយសារគូសខុសឬខូច ក្រុមបោះឆ្នោតត្រូវយកសន្លឹកឆ្នោតដែលបានគូសខុសពីអ្នកបោះឆ្នោតវិញ បន្ទាប់មកទើបអាចចែកសន្លឹកឆ្នោតថ្មីឱ្យបាន។

**សំណួរ ២៦**. ក្នុងករណីណាខ្លះ អ្នកបោះឆ្នោតអាចស្នើឱ្យអ្នកផ្សេងជួយគូសសន្លឹកឆ្នោត ឬជួយបោះឆ្នោតជំនួសបាន ?

**ចម្លើយ៖**

អ្នកបោះឆ្នោតដែលមិនអាចគូសសន្លឹកឆ្នោតដោយខ្លួនឯងបាន អាចស្នើឱ្យអ្នកផ្សេងជួយគូសសន្លឹកឆ្នោតជំនួសបាន ប៉ុន្តែត្រូវបោះដោយខ្លួនឯង។ អ្នកដែលជួយគូសសន្លឹកឆ្នោតត្រូវអានឈ្មោះ និងនាមត្រកូលរបស់បេក្ខជនទាំងអស់ ដែលមាននៅក្នុងសន្លឹកឆ្នោតឱ្យពេញលេញ ដើម្បីឱ្យអ្នកបោះឆ្នោតសម្រេចចិត្តដោយខ្លួនឯង។

អ្នកដែលជួយគូសសន្លឹកឆ្នោត ត្រូវគូសតាមបំណងពិតប្រាកដរបស់អ្នកបោះឆ្នោតដែលស្នើឱ្យជួយនិងត្រូវធានាការសម្ងាត់នៃសន្លឹកឆ្នោត។ បន្ទាប់ពីគូសសន្លឹកឆ្នោតរួច ត្រូវប្រគល់សន្លឹកឆ្នោតឱ្យអ្នកបោះឆ្នោតវិញ ដើម្បីឱ្យអ្នកបោះឆ្នោតយកទៅបោះចូលក្នុងប្រអប់ឆ្នោតដោយខ្លួនឯង។ ចំពោះជនពិការ មនុស្សចាស់ជរា ឬករណីផ្សេងៗ ដែលមិនអាចយកសន្លឹកឆ្នោតទៅបោះចូលក្នុង ប្រអប់ឆ្នោត បាន អាចស្នើឱ្យអ្នកផ្សេងជួយបោះសន្លឹកឆ្នោតចូលក្នុងហិបឆ្នោត។

**សំណួរ ២៧**. តើភារកិច្ចរបស់ប្រជាជនទីក្រុង ចំពោះការបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា នីតិកាលទី១៦ និងបោះឆ្នោតជ្រើសរើសតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦ - ២០៣១ មានអ្វីខ្លះ ?

**ចម្លើយ៖**

ដើម្បីឲ្យការបោះឆ្នោតជ្រើសតាំងតំណាងរដ្ឋសភា នីតិកាលទី ១៦ និងការបោះឆ្នោតជ្រើសរើសតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦ - ២០៣១ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៥/៣/២០២៦ ដើម្បីទទួលបានលទ្ធផលល្អ កម្មាភិបាល យុទ្ធជននិងប្រជាជននៅទីក្រុងកឹងធើ ត្រូវអនុវត្តឱ្យបានល្អនូវការងារដូចខាងក្រោម៖

- អ្នកបោះឆ្នោតត្រូវយល់ដឹងច្បាស់ អំពីសិទ្ធិនិងកាតព្វកិច្ចរបស់ពលរដ្ឋក្នុងការបោះឆ្នោតនិងការឈរឈ្មោះបោះឆ្នោត; ត្រូវយល់ដឹងច្បាស់អំពីបទដ្ឋានរបស់តំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជន ដើម្បីជ្រើសរើសនិងបោះឆ្នោតឱ្យអ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សមស្រប ចូលរួមក្នុងរដ្ឋសភា និងក្រុមប្រឹក្សាប្រជាជន។

- ចូលរួមយ៉ាងសកម្មក្នុងការងារផលិត ជំរុញការចលនាប្រឡងប្រណាំងស្នេហាជាតិ; ចូលរួមពេញលេញក្នុងកិច្ចប្រជុំជួបជាមួយអ្នកបោះឆ្នោត និងសកម្មភាពផ្សព្វផ្សាយអំពីការបោះឆ្នោត; រួមចំណែកធ្វើឱ្យថ្ងៃបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា នីតិកាលទី ១៦ និងតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ ក្លាយជាព្រឹត្តិការណ៍ធំមួយរបស់ប្រជាជនទាំងមូល។

- អ្នកបោះឆ្នោតគ្រប់រូប ត្រូវចូលរួមបោះឆ្នោតដោយស្ម័គ្រចិត្ត; ផ្សព្វផ្សាយនិងលើកទឹកចិត្តសាច់ញាតិឱ្យខ្ទះខ្មែងចូលរួមបោះឆ្នោតយ៉ាងសកម្មនិងគ្រប់គ្នា នៅថ្ងៃទី ១៥/៣/២០២៦; អនុវត្តឱ្យបានល្អតាមបទប្បញ្ញត្តិស្តីពីការបោះឆ្នោត។

- លើកកម្ពស់ការប្រុងប្រយ័ត្ន និងរួមចំណែកប្រយុទ្ធប្រឆាំងនឹងមតិយោបល់បំភាន់ការរៀបចំផែនការ ឬសកម្មភាពដែលមានបំណងបំផ្លាញការបោះឆ្នោត។

## ជំពូកទី IV - ចំនួនអង្គភាពបោះឆ្នោតតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុងកឹងធើ អាណត្តិកាល ២០២៦ - ២០៣១

**សំណួរ ២៨**. អាណត្តិកាល ២០២៦ - ២០៣១ ទីក្រុងកឹងធើ មានតំណាងប៉ុន្មានរូប ត្រូវបានបោះឆ្នោតចូលទៅក្នុងរដ្ឋសភា នីតិកាលទី ១៦ ? ហើយមានតំណាងប៉ុន្មានរូប ត្រូវបានបោះឆ្នោតចូលទៅក្នុងក្រុមប្រឹក្សាប្រជាជនទីក្រុងនិងថ្នាក់ឃុំ?

**ចម្លើយ៖**

យោងតាមមាត្រា ៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា និងតំណាងក្រុមប្រឹក្សាប្រជាជន ឆ្នាំ២០១៥៖ ចំនួនតំណាងរដ្ឋសភាសរុបរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម មិនលើសប្រាំរយ (៥០០) រូប។

សម្រាប់អង្គភាពទីក្រុងកឹងធើ ត្រូវបានបែងចែករចនាសម្ព័ន្ធ និងចំនួនតំណាងរដ្ឋសភា នីតិកាលទី ១៦ ចំនួន ១៨ រូប។ ក្នុងនោះ មានចំនួនតំណាងដែលរស់នៅនិងធ្វើការនៅ មូលដ្ឋាន ១០ រូប និងតំណាងដែលមជ្ឈិមឧទ្ទេសនាម ០៨ រូប។

អាណត្តិកាល ២០២៦ - ២០៣១ ក្រុមប្រឹក្សាប្រជាជនទីក្រុងកឹងធើ មានតំណាងចំនួន ៨៤ រូប និងថ្នាក់ឃុំ សង្កាត់មានតំណាងសរុប ២.២១២ រូប។

**សំណួរ ២៩**. ទីក្រុងកឹងធើ មានមណ្ឌលបោះឆ្នោតប៉ុន្មាន សម្រាប់ការបោះឆ្នោតតំណាងរដ្ឋសភា និងការបោះឆ្នោតតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ ?

**ចម្លើយ៖**

- **សម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា៖** ទីក្រុងកឹងធើ មានមណ្ឌលបោះ

ឆ្នោតតំណាងរាស្ត្រ នីតិកាលទី ១៦ ចំនួន ០៦ រួមមាន៖

មណ្ឌលបោះឆ្នោតលេខ ១ (បណ្តាសង្កាត់៖ ហឹងភូ កាយរ៉ាំង អាងបិញ អាងតឹង និញកេវ កាយខេ បិញថ្វី ឡុងតៀង ថើយអាងដុង គឿកថើយ អូរម៉ូង ថើយឡុង និងបណ្តាឃុំ៖ គ្រឿងថាញ់ គ្រឿងឡុង ផុងដៀង ញើងអាយ);

មណ្ឌលបោះឆ្នោតលេខ ២ (បណ្តាសង្កាត់៖ ធ្វឹងហឹង តឹងឡុក ត្រុងញឹក ថូកណូក និង បណ្តាឃុំ៖ វិញទ្រិញ វិញថាញ់ ថាញ់ក្វើយ ថាញ់អាង ថាញ់ភូ ត្រុងហឹង ថើយហឹង កើ-ដ ដុងធ្វឹង ដុងហ៊ីប ថើយឡាយ គ្រឿងស្វឹង);

មណ្ឌលបោះឆ្នោតលេខ ៣ (បណ្តាសង្កាត់៖ ឡុងបិញ ឡុងមី ឡុងភូ១ វីតឹង វីថាញ និង បណ្តាឃុំ៖ ថាញ់ស្វឹង តឹងហ្វា វីថាញ១ គ្រឿងឡុងតៃ ហ្វាលីវ វិញវៀង លឿងតឹម សាភៀង វិញ ធ្វឹងដុង វីធ្វី វិញតឿង ហ្វាអាង ភឿងបិញ ពុងហ៊ីប តឹងបិញ ថាញ់ហ្វា);

មណ្ឌលបោះឆ្នោតលេខ ៤ (បណ្តាសង្កាត់៖ ង៉ាបៃ ដាយថាញ់ និងបណ្តាឃុំ៖ ហ៊ីបហឹង តឹងភឿកហឹង ដុងភឿក ចូវថាញ់ ភូហូវ អាងឡាកថូង ផុងណឹម ថើយអាងហោយ ញើងមី កេសាត់ ដាយហាយ ហូដាក់គៀង ភូតឹម ធ្វឹងហ្វា អាងនិញ);

មណ្ឌលបោះឆ្នោតលេខ ៥ (បណ្តាសង្កាត់៖ ង៉ាណាំ មីក្វើយ វិញភឿក វិញចូវ និងបណ្តា ឃុំ៖ មីហឿង មីទូ ឡុងហឹង មីភឿក តឹងឡុង វិញឡើយ ភូឡុក ឡឹមតឹង យ៉ាហ្វា ញូយ៉ា ហ្វាទូ ង៉ុកតូ ថាញ់ថើយអាង ឡាយហ្វា វិញហាយ);

មណ្ឌលបោះឆ្នោតលេខ ៦ (បណ្តាសង្កាត់៖ ខាញ់ហ្វា សុកត្រាំង ភូឡើយ មីស្វៀង និងបណ្តាឃុំ៖ លិតហោយទឿង លីវទូ តាយវ៉ាំង ត្រឹងដេ កូវឡាវយុង អាងថាញ់ ឡុងភូ តឹងថាញ់ ដាយង៉ៃ គ្រឿងខាញ់)។

**សម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ នៅទីក្រុងកឹងធើ៖** ថ្នាក់ទីក្រុង មានមណ្ឌលបោះឆ្នោតចំនួន ២៨ និងថ្នាក់ឃុំ មានមណ្ឌលបោះឆ្នោតចំនួន ៦៦៥។

**សំណួរ ៣០៖** អាណត្តិកាល ២០២៦-២០៣១ ទីក្រុងកឹងធើ មានក្រុមបោះឆ្នោតសម្រាប់ ការបោះឆ្នោតតំណាងរាស្ត្រ និងបោះឆ្នោតតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ចំនួនប៉ុន្មាន?

**ចម្លើយ៖**

អាណត្តិកាល ២០២៦-២០៣១ ទីក្រុងកឹងធើ មានក្រុមរដ្ឋបាលថ្នាក់ឃុំនិងសង្កាត់ចំនួន ១០៣ និងមានក្រុមបោះឆ្នោតចំនួន ២.៦១៤ សម្រាប់ការបោះឆ្នោតតំណាងរាស្ត្រ និងបោះ ឆ្នោតតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់។

**សំណួរ ៣១**: ចំនួនក្រុមបោះឆ្នោតសម្រាប់ការបោះឆ្នោតតំណាងរាស្ត្រ នីតិកាលទី១៦ និង ការបោះឆ្នោតតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦-២០៣១ នៅតាមឃុំ សង្កាត់លើភូមិដ្ឋានទីក្រុងកឹងផើ មានប៉ុន្មាន?

**ចម្លើយ៖**

ក្រុមបោះឆ្នោតសម្រាប់ការបោះឆ្នោតតំណាងរាស្ត្រ នីតិកាលទី ១៦ និងការបោះឆ្នោតតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦ - ២០៣១ នៅតាមឃុំ សង្កាត់លើភូមិដ្ឋានទីក្រុងកឹងផើ ដោយមានចំនួនជាក់ស្តែងដូចខាងក្រោម៖

| លរ | អង្គភាពរដ្ឋបាលថ្នាក់ឃុំសង្កាត់ | ចំនួនក្រុមបោះឆ្នោត | ចំនួនតំណាងរាស្ត្រ នីតិកាលទី១៦ | ចំនួនតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុង |
|---|---|---|---|---|
| ១ | សង្កាត់ហឹងភូ | ៣១ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ២ | សង្កាត់កាយរាំង | ៣២ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៣ | សង្កាត់អាងបិញ | ១៧ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៤ | សង្កាត់តឹងអាង | ៣៦ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៥ | សង្កាត់និញកេវ | ៤២ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៦ | សង្កាត់កាយខេ | ២៣ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះ ឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |

| លរ | អង្គភាពរដ្ឋបាលថ្នាក់ឃុំសង្កាត់ | ចំនួនក្រុមបោះឆ្នោត | ចំនួនតំណាងរដ្ឋសភានីតិកាលទី១៦ | ចំនួនតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុង |
|---|---|---|---|---|
| ៧ | សង្កាត់បិញធ្វី | ៣៤ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៨ | សង្កាត់ឡុងត្វៀង | ២៦ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៩ | សង្កាត់ថើយអាងដុង | ១៦ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ១០ | សង្កាត់ភឿកថើយ | ៣៦ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ១១ | សង្កាត់អូរម៉ុង | ៤៨ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ១២ | សង្កាត់ថើយឡុង | ៣៥ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ១៣ | សង្កាត់ធ្វឹងហឹង | ២២ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ១៤ | សង្កាត់តឹងឡុក | ២០ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ១៥ | សង្កាត់ត្រុងញ៉ឹក | ២០ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; |

| លរ | អង្គភាពរដ្ឋបាលថ្នាក់ឃុំសង្កាត់ | ចំនួនក្រុមបោះឆ្នោត | ចំនួនតំណាងរដ្ឋសភានីតិកាលទី១៦ | ចំនួនតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុង |
|---|---|---|---|---|
| | | | បោះឆ្នោតជ្រើសរើស ៣ រូប | បោះឆ្នោតជ្រើសរើស ៣ រូប |
| ១៦ | សង្កាត់ថូកណ្ដូក | ៣៣ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ១៧ | ឃុំវិញទ្រិញ | ២២ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ១៨ | ឃុំវិញចាញ់ | ២១ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ១៩ | ឃុំចាញ់ក្ញើយ | ២៨ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ២០ | ឃុំចាញ់អាង | ១៧ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ២១ | ឃុំចាញ់ភូ | ១៧ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៧៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ២២ | ឃុំត្រុងហឹង | ២៧ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៧៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ២៣ | ឃុំថើយហឹង | ៩ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៧៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ២៤ | ឃុំកើ-ដ | ២៥ | *មណ្ឌលបោះឆ្នោតលេខ ២៖* | *មណ្ឌលបោះឆ្នោតលេខ ៧៖* |

| លរ | អង្គភាពរដ្ឋបាលថ្នាក់ឃុំសង្កាត់ | ចំនួនក្រុមបោះឆ្នោត | ចំនួនតំណាងរដ្ឋសភានីតិកាលទី១៦ | ចំនួនតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុង |
|---|---|---|---|---|
| | | | បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ២៥ | ឃុំដុងធ្វឹង | ១៦ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ២៦ | ឃុំដុងហ៊ីប | ១៧ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ២៧ | ឃុំថើយឡាយ | ២៦ | *មណ្ឌលបោះឆ្នោតលេខ ២* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ២៨ | ឃុំត្រៀងស៊ឹង | ២៣ | *មណ្ឌលបោះឆ្នោតលេខ ២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ២៩ | ឃុំត្រៀងចាញ់ | ២៣ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៩៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៣០ | ឃុំត្រៀងឡុង | ២០ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៩៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៣១ | ឃុំផុងដៀង | ៣៤ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៩៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៣២ | ឃុំញឿងអាយ | ២៤ | *មណ្ឌលបោះឆ្នោតលេខ ១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ៩៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |

| លរ | អង្គភាពរដ្ឋបាលថ្នាក់ឃុំសង្កាត់ | ចំនួនក្រុមបោះឆ្នោត | ចំនួនតំណាងរដ្ឋសភានីតិកាលទី១៦ | ចំនួនតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុង |
|---|---|---|---|---|
| ៣៣ | ឃុំថាញ់ស្ទឹង | ២៥ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១០៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៣៤ | ឃុំតឹងហ្វា | ២៣ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ១០៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៣៥ | ឃុំត្រឿងទ្បុងតៃ | ១៨ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១០៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៣៦ | ឃុំវីថាញ១ | ៣៩ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៣៧ | សង្កាត់វីតឹង | ២០ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៣៨ | សង្កាត់វីថាញ | ១៩ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ១១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៣៩ | ឃុំហ្វាលឺវ | ១៩ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ១២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៤០ | ឃុំវិញវៀង | ១៣ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ១២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៤១ | ឃុំលឿងតឹម | ១៥ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; | *មណ្ឌលបោះឆ្នោតលេខ១២៖* បេក្ខជនឈរឆ្នោត ៥ រូប; |

| លរ | អង្គភាពរដ្ឋបាលថ្នាក់ឃុំសង្កាត់ | ចំនួនក្រុមបោះឆ្នោត | ចំនួនតំណាងរដ្ឋសភានីតិកាលទី១៦ | ចំនួនតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុង |
|---|---|---|---|---|
| | | | បោះឆ្នោតជ្រើសរើស ៣ រូប | បោះឆ្នោតជ្រើសរើស ៣ រូប |
| ៤២ | ឃុំសាភៀង | ១៩ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៤៣ | ឃុំវិញធ្វឹងដុង | ២៣ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៤៤ | ឃុំវីធ្វី | ២៣ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៤៥ | ឃុំវិញតឿង | ២៥ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៤៦ | ឃុំហ្វាអាង | ២១ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៤៧ | សង្កាត់ឡុងបិញ | ១៣ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៤៨ | សង្កាត់ឡុងមី | ២១ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៤៩ | សង្កាត់ឡុងភូ១ | ២១ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៥០ | ឃុំភឿងបិញ | ២៩ | *មណ្ឌលបោះឆ្នោតលេខ ៣៖* | *មណ្ឌលបោះឆ្នោតលេខ ១៤៖* |

| លរ | អង្គភាពរដ្ឋបាល ថ្នាក់ឃុំសង្កាត់ | ចំនួនក្រុមបោះឆ្នោត | ចំនួនតំណាងរដ្ឋសភា នីតិកាលទី១៦ | ចំនួនតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុង |
|---|---|---|---|---|
| | | | បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៥១ | ឃុំហ៊ីបហឹង | ២០ | *មណ្ឌលបោះឆ្នោតលេខ ៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៥២ | ឃុំតឹងភឿកហឹង | ២០ | *មណ្ឌលបោះឆ្នោតលេខ ៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៥៣ | សង្កាត់ង៉ាបៃ | ២០ | *មណ្ឌលបោះឆ្នោតលេខ ៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៥៤ | សង្កាត់ដាយថាញ | ២៣ | *មណ្ឌលបោះឆ្នោតលេខ ៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៥៥ | ឃុំផុងហ៊ីប | ១៩ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៥៦ | ឃុំតឹងប៊ិញ | ២៤ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៥៧ | ឃុំថាញ់ហ្វា | ៦០ | *មណ្ឌលបោះឆ្នោតលេខ ៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៥៨ | ឃុំផុងភឿក | ២៦ | *មណ្ឌលបោះឆ្នោតលេខ ៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៧៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |

| លរ | អង្គភាពរដ្ឋបាលថ្នាក់ឃុំសង្កាត់ | ចំនួនក្រុមបោះឆ្នោត | ចំនួនតំណាងរដ្ឋសភានីតិកាលទី១៦ | ចំនួនតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុង |
|---|---|---|---|---|
| ៥៩ | ឃុំចូវថាញ់ | ១៩ | *មណ្ឌលបោះឆ្នោតលេខ ៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៧៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៦០ | ឃុំភូហូវ | ២២ | *មណ្ឌលបោះឆ្នោតលេខ ៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៧៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៦១ | ឃុំអាងឡាកថូង | ៣៤ | *មណ្ឌលបោះឆ្នោតលេខ ៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៦២ | ឃុំផុងណឹម | ៦ | *មណ្ឌលបោះឆ្នោតលេខ ៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៦៣ | ឃុំថើយអាងហោយ | ២៤ | *មណ្ឌលបោះឆ្នោតលេខ ៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៦៤ | ឃុំញឿងមី | ៣៤ | *មណ្ឌលបោះឆ្នោតលេខ ៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៦៥ | ឃុំកេសាត់ | ៣១ | *មណ្ឌលបោះឆ្នោតលេខ ៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៦៦ | ឃុំដាយហាយ | ២៩ | *មណ្ឌលបោះឆ្នោតលេខ ៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៩៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៦៧ | ឃុំហូដាក់កៀង | ២៥ | *មណ្ឌលបោះឆ្នោតលេខ ៨៖* បេក្ខជនឈរឆ្នោត ៥ រូប; | *មណ្ឌលបោះឆ្នោតលេខ ១៩៖* បេក្ខជនឈរឆ្នោត ៥ រូប; |

| លរ | អង្គភាពរដ្ឋបាលថ្នាក់ឃុំសង្កាត់ | ចំនួនក្រុមបោះឆ្នោត | ចំនួនតំណាងរដ្ឋសភានីតិកាលទី១៦ | ចំនួនតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុង |
|---|---|---|---|---|
| | | | បោះឆ្នោតជ្រើសរើស ៣ រូប | បោះឆ្នោតជ្រើសរើស ៣ រូប |
| ៦៨ | ឃុំភូតឹម | ២៥ | *មណ្ឌលបោះឆ្នោតលេខ ៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៩៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៦៩ | ឃុំធ្វឹងហ្វា | ១២ | *មណ្ឌលបោះឆ្នោតលេខ ៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៩៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៧០ | ឃុំអាងនិញ | ២៦ | *មណ្ឌលបោះឆ្នោតលេខ ៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ១៩៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៧១ | ឃុំមីហឿង | ៣៥ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២០៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៧២ | ឃុំមីទូ | ២៤ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២០៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៧៣ | ឃុំឡុងហឹង | ២២ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២០៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៧៤ | ឃុំមីភឿក | ១៤ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២០៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៧៥ | សង្កាត់ង៉ាណាំ | ៤៣ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៧៦ | ឃុំតឹងឡុង | ២២ | *មណ្ឌលបោះឆ្នោតលេខ ៥៖* | *មណ្ឌលបោះឆ្នោតលេខ ២១៖* |

| លរ | អង្គភាពរដ្ឋបាលថ្នាក់ឃុំសង្កាត់ | ចំនួនក្រុមបោះឆ្នោត | ចំនួនតំណាងរដ្ឋសភានីតិកាលទី១៦ | ចំនួនតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុង |
|---|---|---|---|---|
| | | | បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៧៧ | សង្កាត់មីក្វើយ | ២៧ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២១៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៧៨ | ឃុំវិញទ្បើយ | ២២ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើស រើស ៣ រូប |
| ៧៩ | ឃុំភូឡុក | ៣៥ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៨០ | ឃុំឡឹមតឹង | ១៩ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៨១ | ឃុំយ៉ាហ្វា | ៣៦ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២២៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៨២ | ឃុំញូយ៉ា | ៣៩ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ២៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៨៣ | ឃុំហ្វាទូ | ២៦ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ២៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៨៤ | ឃុំង៉ុកតូ | ៣៧ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ២៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |

| លរ | អង្គភាពរដ្ឋបាលថ្នាក់ឃុំសង្កាត់ | ចំនួនក្រុមបោះឆ្នោត | ចំនួនតំណាងរដ្ឋសភានីតិកាលទី១៦ | ចំនួនតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុង |
|---|---|---|---|---|
| ៨៥ | ឃុំថាញ់ថើយអាង | ១៨ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ២៣៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៨៦ | ឃុំឡាយហ្វា | ១៦ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៨៧ | សង្កាត់វិញភឿក | ២៨ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៨៨ | សង្កាត់វិញចូវ | ៣៦ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៨៩ | ឃុំវិញហាយ | ១៥ | *មណ្ឌលបោះឆ្នោតលេខ ៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២៤៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៩០ | សង្កាត់ខាញ់ហ្វា | ៣១ | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៩១ | ឃុំលិតហោយទឿង | ១៣ | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៩២ | ឃុំលីវទូ | ២២ | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២៥៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៩៣ | ឃុំតាយវ៉ាំង | ២៧ | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; | *មណ្ឌលបោះឆ្នោតលេខ ២៥៖* បេក្ខជនឈរឆ្នោត ៥ រូប; |

| លរ | អង្គភាពរដ្ឋបាលថ្នាក់ឃុំសង្កាត់ | ចំនួនក្រុមបោះឆ្នោត | ចំនួនតំណាងរដ្ឋសភានីតិកាលទី១៦ | ចំនួនតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុង |
|---|---|---|---|---|
| | | | បោះឆ្នោតជ្រើសរើស ៣ រូប | បោះឆ្នោតជ្រើសរើស ៣ រូប |
| ៩៤ | ឃុំត្រើងដេ | ៣១ | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៩៥ | ឃុំកូវឡាវយុង | ៣២ | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៩៦ | ឃុំអាងថាញ់ | ២៦ | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ ២៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៩៧ | ឃុំឡុងភូ | ១៧ | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ២៧៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៩៨ | ឃុំតឹងថាញ់ | ២៦ | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ២៧៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ៩៩ | ឃុំដាយង៉ៃ | ១៨ | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ២៧៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ១០០ | ឃុំត្រឿងខាញ់ | ២៧ | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ២៧៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ១០១ | សង្កាត់សុកត្រាំង | ៣៤ | *មណ្ឌលបោះឆ្នោតលេខ ៦៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | *មណ្ឌលបោះឆ្នោតលេខ២៨៖* បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ១០២ | សង្កាត់ភូឡើយ | ៤១ | *មណ្ឌលបោះឆ្នោតលេខ ៦៖* | *មណ្ឌលបោះឆ្នោតលេខ២៨៖* |

| លរ | អង្គភាពរដ្ឋបាលថ្នាក់ឃុំសង្កាត់ | ចំនួនក្រុមបោះឆ្នោត | ចំនួនតំណាងរដ្ឋសភានីតិកាលទី១៦ | ចំនួនតំណាងក្រុមប្រឹក្សាប្រជាជនទីក្រុង |
|---|---|---|---|---|
| | | | បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| ១០៣ | សង្កាត់មីស្មៀង | ៣៣ | ***មណ្ឌលបោះឆ្នោតលេខ ៦៖*** បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប | ***មណ្ឌលបោះឆ្នោតលេខ២៨៖*** បេក្ខជនឈរឆ្នោត ៥ រូប; បោះឆ្នោតជ្រើសរើស ៣ រូប |
| **សរុបក្រុមបោះឆ្នោត៖** | | **២.៥៩៨** | | |

**សំណួរ ៣២៖** ពាក្យស្លោកផ្សព្វផ្សាយមួយចំនួន សម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា នីតិកាលទី ១៦ និងតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦ - ២០៣១?

**ចម្លើយ៖**

ពាក្យស្លោកផ្សព្វផ្សាយមួយចំនួន សម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា នីតិកាលទី ១៦ និងតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦ - ២០៣១ មានដូចជា៖

១. សូមស្វាគមន៍យ៉ាងកក់ក្ដៅ ថ្ងៃបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា នីតិកាលទី ១៦ និង តំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦ - ២០៣១!

២. ថ្ងៃទី១៥-៣-២០២៦ អ្នកបោះឆ្នោតទូទាំងប្រទេស ទៅចូលរួមបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា នីតិកាលទី ១៦ និងតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦ - ២០៣១!

៣. ការបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា នីតិកាលទី ១៦ និងតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល២០២៦-២០៣១ គឺជាព្រឹត្តិការណ៍ធំមួយរបស់ទូទាំងប្រជាជន!

៤. ថ្ងៃបោះឆ្នោត គឺជាថ្ងៃបុណ្យនៃសាមគ្គីភាពដ៏ធំរបស់ទូទាំងជនជាតិ!

៥. ថ្ងៃបោះឆ្នោត - ថ្ងៃបុណ្យនៃការជឿជាក់ សាមគ្គីភាពនិងក្ដីប្រាថ្នារបស់វៀតណាម!

៦. ការបោះឆ្នោត រួមចំណែកកសាងប្រទេសនីតិរដ្ឋសង្គមនិយមវៀតណាមឱ្យរឹងមាំ!

៧. បោះឆ្នោតដើម្បីជ្រើសរើសអ្នកដែលមានចិត្តស្មោះត្រង់ មានសមត្ថភាព និងបម្រើប្រជាជនដោយអស់ពីចិត្ត!

៨. លើកកម្ពស់សិទ្ធិជាម្ចាស់របស់ប្រជាជន តាមរយៈការបោះឆ្នោតប្រជាធិបតេយ្យ បើកចំហ និងតម្លាភាព!

៩. ការចូលរួមបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា នីតិកាលទី ១៦ និងតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦-២០៣១ គឺជាសិទ្ធិនិងកាតព្វកិច្ចដ៏ពិសិដ្ឋរបស់ពលរដ្ឋគ្រប់រូប!

១០. ជ្រើសរើសដោយប្រាជ្ញា ចំពោះអ្នកដែលស័ក្តិសមតំណាងឱ្យប្រជាជន!

១១. អ្នកបោះឆ្នោតនៅទីក្រុងកឹងធើ ចូលរួមយ៉ាងសកម្មក្នុងការបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា អាណត្តិកាលទី១៦ និងតំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦-២០៣១!

១២. សន្លឹកឆ្នោតមួយសន្លឹក គឺជាការជឿជាក់មួយជាកាតព្វកិច្ចមួយចំពោះមាតុភូមិ!

១៣. ជ្រើសរើសដោយប្រាជ្ញានូវអ្នកដែលមានគុណធម៌ និងសមត្ថភាពគ្រប់គ្រាន់ចូលទៅក្នុងរដ្ឋសភានិងក្រុមប្រឹក្សាប្រជាជន!

១៤. អ្នកបោះឆ្នោតទូទាំងប្រទេស ស្រុះចិត្តគ្នាបោះឆ្នោតដើម្បីព្រួតដៃកសាងប្រទេសជាតិសម្បូរសប្បាយ!

១៥. ប្រជាពលរដ្ឋទាំងអស់ចូលរួមបោះឆ្នោត ដើម្បីរួមចំណែកកសាងរដ្ឋអំណាចស្អាតស្អំរឹងមាំ!

១៦. សន្លឹកឆ្នោតមួយសន្លឹក រួមចំណែកធ្វើឱ្យប្រទេសអភិវឌ្ឍន៍ខ្លាំងក្លា និងសម្បូររុងរឿង!

១៧. រដ្ឋសភាវៀតណាម - ជាស្ថាប័នតំណាងកំពូលរបស់ប្រជាជន ជាស្ថាប័នអំណាចរដ្ឋខ្ពស់បំផុតនៃសាធារណរដ្ឋសង្គមនិយមវៀតណាម!

១៨. រដ្ឋសភាវៀតណាម គឺជានិមិត្តរូបនៃកម្លាំងស្មារតីមហាសាមគ្គីដ៏ធំធេងរបស់បណ្តាជនជាតិវៀតណាមទាំងមូល!

១៩. រដ្ឋសភា នីតិកាលទី១៦ គឺជាតំណាងនៃប្រាជ្ញា ឆន្ទៈនិងគោលបំណងរបស់ប្រជាជន!

២០. ទូទាំងបក្សភាគ ទូទាំងប្រជាជន ទូទាំងកងទ័ពនៅទីក្រុងកឹងធើ ប្រឡងប្រណាំងបង្កើតស្នាដៃ ដើម្បីអបអរសាទរការបោះឆ្នោតជ្រើសរើសតំណាងរដ្ឋសភា នីតិកាលទី១៦និង

តំណាងក្រុមប្រឹក្សាប្រជាជនគ្រប់ថ្នាក់ អាណត្តិកាល ២០២៦ - ២០៣១!

២១. បក្សកុម្មុយនីស្តវៀតណាមរុងរឿងម៉ឺនឆ្នាំ!

២២. សាធារណរដ្ឋសង្គមនិយមវៀតណាមម៉ឺនឆ្នាំ!

២៣. លោកប្រធានហូជីមិញដ៏មហិមា រស់ជានិច្ចក្នុងបុព្វហេតុរបស់យើង!

MỤC LỤC

- Phần I - Những vấn đề chung 2
- Phần II - Người ứng cử, cử tri và vận động bầu cử 5
- Phần III - Ngày bầu cử, nguyên tắc, trình tự bỏ phiếu; trách nhiệm của người dân 8
- Phần IV - Số lượng đơn vị bầu cử, đại biểu quốc hội và đại biểu hội đồng nhân dân thành phố Cần Thơ nhiệm kỳ 2026 - 2031 10

Số lượng .... bản, khổ 20 x 29cm. In tại Công ty Cổ phần In Tổng hợp Cần Thơ. Số 500, đường 30/4, phường Tân An, thành phố Cần Thơ. Giấy phép xuất bản số: ..../GP-SVHTTDL do Sở Văn hóa, Thể thao và Du lịch cấp ngày ....-...-2026. In xong và nộp lưu chiểu tháng ... năm 2026.